ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

# ផែនការយុទ្ធសាស្ត្រ
# អភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ
# ២០២៣ - ២០២៧



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

# ផែនការយុទ្ធសាស្ត្រ
# អភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ
# ២០២៣ - ២០២៧

# បុព្វកថា

វិស័យមាត្រាសាស្ត្រ គឺជាវិស័យមួយក្នុងចំណោមវិស័យសំខាន់ផ្សេងទៀត ដែលជាកម្លាំងចលករដ៏រឹងមាំ បាន និងកំពុងជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ និងបណ្តាប្រទេសអភិវឌ្ឍជឿនលឿនលើសកលលោក។ វិស័យមាត្រាសាស្ត្របានដើរតួនាទីយ៉ាងសំខាន់ ក្នុងជីវភាពរស់នៅរបស់យើងជាអាទិ៍ ការជួយគាំទ្រសុខមាលភាពរបស់សង្គម និងទំនើបកម្ម ដោយគាំទ្រលើផ្នែកពាណិជ្ជកម្ម ឧស្សាហកម្ម សុខភាព សុវត្ថិភាព បរិស្ថាន និងសេវាកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស និងបទបញ្ជាបច្ចេកទេស។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់យកចក្ខុវិស័យមាត្រាសាស្ត្រ គឺជាវិស័យគាំទ្រ ដែលធ្វើឱ្យប្រសើរឡើងផ្នែកឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ ការផ្លាស់ប្តូរពាណិជ្ជកម្ម និងសេវាកម្ម ដើម្បីផ្តល់ការទុកចិត្តដល់អ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់នៅកម្ពុជា និងសកលលោក។

ដើម្បីឱ្យការបំពេញភារកិច្ចសម្រេចបានលទ្ធផលជោគជ័យ និងផ្លែផ្កាជាវិជ្ជមានតាមការគ្រោងទុក ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានរៀបចំ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ ២០២៣-២០២៧** ដែលជាយុទ្ធសាស្ត្រដ៏មានសារសំខាន់ និងចាំបាច់ ក្នុងគោលបំណង និងទិសដៅជួយតម្រង់ទិស ក្នុងការអនុវត្តផែនការសកម្មភាពរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) ដែលជាអង្គភាពជាតិសម្រាប់អនុវត្តការងារមាត្រាសាស្ត្រប្រកបដោយប្រសិទ្ធភាពខ្ពស់ ឈានទៅសម្រេចបាននូវចក្ខុវិស័យឆ្នាំ ២០៣០ និង២០៥០ របស់រាជរដ្ឋាភិបាល។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រនេះ ត្រូវបានរៀបចំឡើង តាមរយៈគម្រោងនៃការពង្រឹងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិក្នុងប្រទេសកម្ពុជា ដោយមានការគាំទ្រយ៉ាងសកម្ម ពីសំណាក់ទីប្រឹក្សាវិទ្យាស្ថានមាត្រាសាស្ត្រជាតិអាល្លឺម៉ង់ (PTB) ដែលជាអ្នកសម្របសម្រួលបច្ចេកទេស និងជាវាគ្មិន ក្នុងការបង្កើតបាននូវធាតុសំខាន់ៗរបស់ផែនការយុទ្ធសាស្ត្រនេះ និងផ្តោតលើការកំណត់ចក្ខុវិស័យសម្រាប់វិស័យមាត្រាសាស្ត្រ ត្រូវបានអភិវឌ្ឍយ៉ាងល្អ ក្នុងការលើកកម្ពស់គុណភាពនៃផលិតកម្ម ធានាដល់ការធ្វើពាណិជ្ជកម្មប្រកបដោយយុត្តិធម៌ និងប្រកួតប្រជែង ដើម្បីរួមចំណែកដល់ការលូតលាស់សេដ្ឋកិច្ចជាតិ និងចក្ខុវិស័យសម្រាប់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) ប្រកបដោយឧត្តមភាពឈានមុខរបស់ប្រទេសកម្ពុជា ដែលមានការទទួលស្គាល់ជាអន្តរជាតិ រួមទាំងបានកំណត់បេសកកម្ម លើការផ្តល់សេវាមាត្រាសាស្ត្រគ្រប់ប្រភេទដល់វិស័យពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម និងវិស័យផ្សេងទៀត ទៅតាមនិយាមដែលទទួលស្គាល់ជាអន្តរជាតិ ដើម្បីធានាសុក្រឹតភាពនៃរង្វាស់រង្វាល់ សំដៅលើកកម្ពស់សុខភាព សុវត្ថិភាព និងបរិស្ថាន។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រនេះ ត្រូវបានតាក់តែង និងកំណត់នូវសសរស្តម្ភយុទ្ធសាស្ត្រចំនួន ០៥ (ប្រាំ) ហើយក្នុងយុទ្ធសាស្ត្រនីមួយៗមានរៀបរាប់អំពីគោលដៅដ៏ជាក់លាក់ ដែលត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ ២០២៧។ យុទ្ធសាស្ត្រទី១-លើកកម្ពស់សេវាមាត្រាសាស្ត្រដែលជួយគាំទ្រទីផ្សារ យុទ្ធសាស្ត្រទី២-ពង្រឹងការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ យុទ្ធសាស្ត្រទី៣-សុខដុមនីយកម្ម និងសមាហរណកម្មការងារមាត្រាសាស្ត្រ យុទ្ធសាស្ត្រទី៤-លើកកម្ពស់ការយល់ដឹងរបស់ អ្នកពាក់ព័ន្ធអំពីមាត្រាសាស្ត្រ និងយុទ្ធសាស្ត្រទី៥-បន្តអភិវឌ្ឍសមត្ថភាព និងពង្រឹងមុខងារគាំទ្រទូទៅ។

ខ្ញុំសូមសម្តែងការកោតសរសើរខ្ពស់ ចំពោះការខិតខំប្រឹងប្រែងគ្រប់តួអង្គពាក់ព័ន្ធ ដែលបានចូលរួមក្នុងដំណើរការកសាង និងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ ២០២៣-២០២៧ នេះ ដែលជាវិស័យមួយនាំឱ្យមានភាពជោគជ័យក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ការផ្តល់អាទិភាពដល់វិស័យមាត្រាសាស្ត្រ គឺជាការសម្រេចចិត្តដ៏សំខាន់មួយ ដែលនឹងអនុញ្ញាតឱ្យប្រទេសកម្ពុជាឈានជើងចូលក្នុងយុគសម័យថ្មី នៃសេដ្ឋកិច្ចទំនើបកម្មឌីជីថល។

ក្នុងនាម **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ខ្ញុំមានសេចក្តីសោមនស្សយ៉ាងក្រៃលែង និងសូមកោតសរសើរចំពោះថ្នាក់ដឹកនាំក្រសួងគ្រប់លំដាប់ថ្នាក់ ក្រុមការងាររបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) និងទីប្រឹក្សាវិទ្យាស្ថានមាត្រាសាស្ត្រជាតិអាល្លឺម៉ង់ (PTB) ដែលបានកសាង និងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រនេះឡើង ដើម្បីបន្តអភិវឌ្ឍវិស័យមាត្រាសាស្ត្រប្រកបដោយគុណភាព និងប្រសិទ្ធភាពស្របតាមបទដ្ឋានក្នុងតំបន់ និងអន្តរជាតិ។

ខ្ញុំសូមឱ្យគ្រប់តួអង្គពាក់ព័ន្ធទាំងឡាយ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ទាំងអស់ ចូលរួមគាំទ្រអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ ២០២៣-២០២៧ ជាប្រព័ន្ធឱ្យទទួលបានជោគជ័យ និងចូលរួមយ៉ាងសកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**

**និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

# មាតិកា


**បុព្វកថា** ........ ១

**សេចក្តីសង្ខេប** ........ ៥

**អក្សរកាត់** ........ ៧

**ជំពូកទី១៖ ទិសដៅគោលនយោបាយជាតិ និងបេសកកម្មអង្គភាពមាត្រាសាស្ត្រជាតិ** ........ ៨

១.១. ទិសដៅគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ ........ ៨

១.២. ប្រវត្តិ និងតួនាទី របស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ........ ៩

១.៣. ភាពចាំបាច់ និងដំណើរការអភិវឌ្ឍយុទ្ធសាស្ត្រមាត្រាសាស្ត្រ ........ ១១

១.៤. ចក្ខុវិស័យ បេសកកម្ម គោលដៅ និងគុណតម្លៃ ........ ១២

១.៤.១. ចក្ខុវិស័យ ........ ១២

១.៤.២. បេសកកម្ម ........ ១៣

១.៤.៣. គោលដៅ ........ ១៣

១.៤.៤. គុណតម្លៃស្នូល ........ ១៣

**ជំពូកទី២៖ បរិបទ និងស្ថានភាពនៃវិស័យមាត្រាសាស្ត្រ** ........ ១៤

២.១. បរិបទនៃមាត្រាសាស្ត្រពិភពលោក ........ ១៤

២.១.១ . មាត្រាសាស្ត្រជាអ្វី? ........ ១៤

២.១.២ . មាត្រាសាស្ត្រជាប្រព័ន្ធ ដែលដំណើរការជាសកល ........ ១៤

២.១.៣ . តួនាទី និងសារសំខាន់នៃមាត្រាសាស្ត្រ ........ ១៦

២.១.៤ . ជំពូកនៃការងារមាត្រាសាស្ត្រ ........ ១៧

២.១.៥ . មាត្រាសាស្ត្រជាផ្នែកដ៏សំខាន់នៃហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ ........ ១៧

២.២. ស្ថានភាពនៃវិស័យមាត្រាសាស្ត្រនៅកម្ពុជា ........ ១៨

២.៣. វឌ្ឍនភាព និងសមិទ្ធផលសំខាន់ៗកន្លងមក ........ ១៩

២.៤. បញ្ហាប្រឈមដែលត្រូវដោះស្រាយ ........ ២០

**ជំពូកទី៣៖ ក្របខណ្ឌយុទ្ធសាស្ត្រវិស័យមាត្រាសាស្ត្រ ២០២៣-២០២៧** ........ ២៣

៣.១. លើកកម្ពស់ និងពង្រីកសេវាកម្មមាត្រាសាស្ត្រដែលជួយគាំទ្រទីផ្សារ ........ ២៥

៣.២. ពង្រឹងការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ ........ ២៥

៣.៣. សុខដុមនីយកម្ម និងសមាហរណកម្មការងារមាត្រាសាស្ត្រ ........ ២៦

៣.៤. លើកកម្ពស់ការយល់ដឹងរបស់អ្នកពាក់ព័ន្ធអំពីមាត្រាសាស្ត្រ ........ ២៦

៣.៥. បន្តអភិវឌ្ឍសមត្ថភាព និងពង្រឹងមុខងារគាំទ្រទូទៅ ........ ២៦

**ជំពូកទី៤៖ ការគៀរគរប្រភពធនធាន** ........ ២៧

**ជំពូកទី៥៖ ការអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ** ........ ២៨
៥.១. ការអនុវត្តផែនការយុទ្ធសាស្ត្រ ........ ២៨
៥.២. ការត្រួតពិនិត្យ និងវាយតម្លៃ ........ ២៩
**ជំពូកទី៦៖ សេចក្តីសន្និដ្ឋាន** ........ ៣០
**ឧបសម្ព័ន្ធទី១៖ ម៉ាទ្រិកសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃ** ........ ៣១
**ឧបសម្ព័ន្ធទី២៖ លទ្ធផលវិភាគស្ថានភាព ម.ម.ជ ដោយប្រើវិធីសាស្ត្រ SWOT** ........ ៤៤
**ឧបសម្ព័ន្ធទី៣៖ សន្ទានុក្រម** ........ ៤៥
**ឧបសម្ព័ន្ធទី៤៖ អ្នកចូលរួមក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ** ........ ៤៩

# សេចក្ដីសង្ខេប

មាត្រាសាស្ត្រ ជាវិទ្យាសាស្ត្រ និងការគ្រប់គ្រងទម្ងន់ និងរង្វាស់រង្វាល់។ បើក្នុងន័យទូលំទូលាយ គឺរាល់អ្វីៗដែលអាចវាស់វាល់បាន ហើយប៉ះពាល់ដោយផ្ទាល់នឹងជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្ស។ ទោះជាយ៉ាងនេះក្ដី នៅកម្ពុជា មាត្រាសាស្ត្រ និងសារសំខាន់របស់វា មិនទាន់បានយល់ដឹងទូលំទូលាយក្នុងចំណោមមហាជនទូទៅនៅឡើយ។ វិស័យមាត្រាសាស្ត្រ បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ ក្នុងការជំរុញ ដល់ការលូតលាស់សេដ្ឋកិច្ចជាតិ តាមរយៈការផ្ដល់រង្វាស់រង្វាល់ដែលមានសុក្រឹតភាព និងអាចជឿទុកចិត្តបាន ដល់វិស័យ ផលិតកម្ម និងវិស័យពាក់ព័ន្ធជាច្រើនផ្សេងទៀត ដើម្បីលើកកម្ពស់គុណភាព សុវត្ថិភាព សុខភាព និងបរិស្ថាន។ ទន្ទឹមនឹងវឌ្ឍនភាពដែលទទួលបាន វិស័យមាត្រាសាស្ត្រនៅកម្ពុជាត្រូវបានមើលឃើញថាមានការអភិវឌ្ឍយឺតនៅឡើយ បើប្រៀបធៀបទៅនឹងបណ្ដាប្រទេសក្នុងតំបន់ និងជួបប្រទះបញ្ហា ប្រឈមជាច្រើនទៀត ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ និងអភិវឌ្ឍន៍បន្ថែម។

វិស័យមាត្រាសាស្ត្រនៅកម្ពុជា កំពុងរួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏ដូចជាគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ នឹងដើរតួជាផែនទីបង្ហាញផ្លូវ ក្នុងការអភិវឌ្ឍវិស័យមាត្រាសាស្ត្រឱ្យកាន់តែរីកចម្រើន។

នេះជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ ៥ ឆ្នាំ លើកទី១ ដែលត្រូវបានចងក្រងឡើង តាមរយៈដំណើរការរៀបចំផែនការ ដែលមានការចូលរួមពីថ្នាក់ដឹកក្រសួង ឧ.វ.ប.ន ថ្នាក់ដឹកនាំ ម.ម.ជ និងអ្នកពាក់ព័ន្ធសំខាន់ៗ រួមទាំងអ្នកប្រើប្រាស់សេវាកម្មមាត្រាសាស្ត្រមកពីវិស័យឯកជនផងដែរ។ ទីប្រឹក្សារបស់វិទ្យាស្ថានមាត្រាសាស្ត្រជាតិអាល្លឺម៉ង់ (PTB) បានជួយសម្របសម្រួលដំណើរការនេះ ហើយក្រុមការងារស្នូលរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដែលមានតំណាងគ្រប់នាយកដ្ឋាន និងការិយាល័យ បានចូលរួមយ៉ាងសកម្ម ក្នុងដំណើរការកសាងផែនការនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានភាពជាម្ចាស់លើលទ្ធផលទទួលបាន។ ទម្រង់នៃការកសាងផែនការនេះ ធ្វើឡើងដោយយកលំនាំតាមគោលការណ៍ណែនាំរបស់ក្រសួងផែនការ ស្ដីពីការកសាងផែនការអភិវឌ្ឍន៍វិស័យ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ ចែកចេញជា ០៦ (ប្រាំមួយ) ជំពូក ដែលអាចសង្ខេបបានជាបួនផ្នែកធំៗ៖

## ១- ទិសដៅនៃគោលនយោបាយ និងបេសកកម្មរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ជំពូកទី១)

ផ្នែកនេះពណ៌នាអំពីភាពប្រទាក់ក្រឡាគ្នារវាងតួនាទីមាត្រាសាស្ត្រ ជាមួយគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល (ពីលំដាប់ជាតិ រហូតដល់លំដាប់វិស័យ) និងទិសដៅរបស់វិស័យមាត្រាសាស្ត្រ (ចក្ខុវិស័យ បេសកកម្ម គោលដៅ)។ ទិសដៅរបស់វិស័យមាត្រាសាស្ត្រមានសង្គតិភាពជាមួយគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាល។

## ២- បរិបទ និងស្ថានភាពនៃវិស័យមាត្រាសាស្ត្រ (ជំពូកទី២)

ផ្នែកនេះពណ៌នាអំពីបរិបទមាត្រាសាស្ត្រពិភពលោក និងស្ថានភាពវិស័យមាត្រាសាស្ត្រនៅកម្ពុជា។ មាត្រាសាស្ត្រ ដែលជាវិទ្យាសាស្ត្រនៃទម្ងន់ និងរង្វាស់រង្វាល់ មិនអាចប្រតិបត្តិជាលក្ខណៈដោយឡែកទៅតាមប្រទេសផ្សេងៗគ្នាបានទេ ប៉ុន្តែតម្រូវឱ្យមានការប្រតិបត្តិស្របគ្នា ដែលមានការទទួលស្គាល់ជាអន្តរជាតិ។ ប្រការនេះ តម្រូវឱ្យតួអង្គប្រតិបត្តិ (ស្ថាប័នមាត្រាសាស្ត្រជាតិ) ស្វែងយល់ឱ្យបានស៊ីជម្រៅលើការប្រតិបត្តិរបស់មាត្រាសាស្ត្រអន្តរជាតិ ដើម្បី

បន្សុំការប្រតិបត្តិមាត្រាសាស្ត្រកម្ពុជា ទៅតាមនិយាមអន្តរជាតិ។ បរិបទមាត្រាសាស្ត្រពិភពលោករួមមាន អត្ថន័យនិងប្រវត្តិនៃមាត្រាសាស្ត្រ វិធីប្រតិបត្តិមាត្រាសាស្ត្រ សារសំខាន់នៃមាត្រាសាស្ត្រ ជំពូកមាត្រាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ ត្រូវបានពន្យល់ក្នុងផ្នែកនេះ ដោយមានបញ្ជាក់ប្រភពឯកសារយោងយ៉ាងច្បាស់លាស់។ ក្នុងផ្នែកនេះដែរ ស្ថានភាពមាត្រាសាស្ត្រនៅកម្ពុជាក៏ត្រូវបានកំណត់ ដែលជាមូលដ្ឋានសម្រាប់លើកយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ និងពង្រឹងវិស័យមាត្រាសាស្ត្រនៅកម្ពុជា។

## ៣- ក្របខណ្ឌយុទ្ធសាស្ត្រវិស័យមាត្រាសាស្ត្រ ២០២៣-២០២៧ សម្រាប់ ៥ ឆ្នាំខាងមុខ (ជំពូកទី៣)

នេះជាផ្នែកស្នូលរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រនៅកម្ពុជា សម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ ដោយស្ថិតនៅក្នុងក្របខណ្ឌនៃគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ (ផ្នែកទី១) និងបរិបទនៃមាត្រាសាស្ត្រអន្តរជាតិ (ផ្នែកទី២)។ ក្នុងផ្នែកនេះ យុទ្ធសាស្ត្រធំៗចំនួន ៥ ត្រូវបានកំណត់ ដូចតទៅ៖ (១)លើកកម្ពស់ និងពង្រីកសេវាកម្មមាត្រាសាស្ត្រដែលជួយគាំទ្រទីផ្សារ (២)ពង្រឹងការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ (៣)សុខដុមនីយកម្ម និងសមាហរណកម្មការងារមាត្រាសាស្ត្រ ដែលជួយគាំទ្រទីផ្សារ (៤)លើកកម្ពស់ការយល់ដឹងរបស់អ្នកពាក់ព័ន្ធអំពីការងារមាត្រាសាស្ត្រ និង(៥)បន្តអភិវឌ្ឍសមត្ថភាព និងពង្រឹងមុខងារគាំទ្រទូទៅ។ យុទ្ធសាស្ត្រទាំងប្រាំនេះ បានក្លាយជាក្របខណ្ឌសម្រាប់បង្កើតសូចនាករ បញ្ជាក់ការទទួលខុសត្រូវរបស់នាយកដ្ឋាន និងបង្កើតផែនការសកម្មភាពសម្រាប់អនុវត្ត។

## ៤- ក្របខណ្ឌសម្រាប់អនុវត្ត (ជំពូកទី៤ ទី៥ និងទី៦)

ផ្នែកនេះពណ៌នាអំពីទិដ្ឋភាពនានា ដែលចាំបាច់សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ ក្នុងនោះរួមមាន៖ ការកៀរគរប្រភពធនធានដើម្បីធ្វើជាហិរញ្ញប្បទានដល់ដំណើរការ និងប្រតិបត្តិការរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដែលជាប្រតិបត្តិករជាតិលើផ្នែកមាត្រាសាស្ត្រ រចនាសម្ព័ន្ធអនុវត្ត-ការបញ្ជាក់តួនាទីរបស់នាយកដ្ឋាននីមួយៗក្នុងការរួមចំណែកទៅសម្រេចយុទ្ធសាស្ត្រ ការបំបែកផែនការយុទ្ធសាស្ត្រឱ្យទៅជាផែនការប្រតិបត្តិប្រចាំឆ្នាំដើម្បីអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ។

សម្រាប់អ្នកពាក់ព័ន្ធ ដើម្បីមានភាពងាយស្រួលយល់ដឹងអំពីផែនការយុទ្ធសាស្ត្រនេះ សន្ទានុក្រមដែលពន្យល់បកស្រាយវាក្យសព្ទមាត្រាសាស្ត្រ ត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធទី៣។

# អក្សរកាត់

| | |
|---|---|
| ក្រសួង ឧ.វ.ប.ន | : ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ម.ម.ជ | : មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ |
| APMP | : Asia Pacific Metrology Programme |
| ACCSQ-WG3 | : ASEAN Consultative Committee on Standard and Quality – Working Group on Metrology |
| APLMF | : Asia-Pacific Legal Metrology Forum |
| ASEAN EGM | : ASEAN Expert Group on Metrology |
| BIPM | : Bureau International des Poids et Mesures / International Bureau of Weights and Measures |
| CAVAC | : Cambodia-Australia Agricultural Value Chain Program |
| CGPM | : Conférence Générale des Poids et Mesures / General Conference on Weights and Measures |
| CIPM | : Comité International des Poids et Mesures / International Committee for Weights and Measures |
| CMC | : Calibration and Measurement Capability |
| CS | : Certificate System |
| D/INM | : Department of Industrial Metrology / នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម |
| D/MLA | : Department of Legislation Metrology / នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ |
| D/MSC | : Department of Scientific Metrology / នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ |
| D/LGM | : Department of Legal Metrology / នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ |
| MISTI | : Ministry of Industry, Science, Technology and Innovation |
| NIM, China | : National Institute of Metrology of China |
| NIMT | : National Institute of Metrology (Thailand) |
| NMC | : National Metrology Center |
| NMI | : National Metrology Institute |
| OIML | : Organisation Internationale de Métrologie Légale / International Organization of Legal Metrology |
| OWS | : One Window Service / ការិយាល័យច្រកចេញចូលតែមួយ របស់ ម.ម.ជ |
| PTB | : Physikalisch-Technische Bundesanstalt / National Metrology Institute (Germany) |
| RMO | : Regional Metrology Organization |
| SI | : International System of Unit |
| SME | : Small and Medium Enterprise |
| SOP | : Standard Operation Procedure |
| TOR | : Terms of Reference |
| UNIDO | : United Nations Development Programme |

# ជំពូកទី១៖ ទិសដៅគោលនយោបាយជាតិ និងបេសកកម្មអង្គភាពមាត្រាសាស្ត្រជាតិ

## ១.១. ទិសដៅគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ

"គ្មានបរិមាណណាមួយ ដែលអាចថ្លឹង និងវាស់វាល់ត្រឹមត្រូវ សុក្រឹត និងទៀងទាត់ ដោយគ្មានមាត្រាសាស្ត្រឡើយ" (OIML 2021)។ មាត្រាសាស្ត្រពាក់ព័ន្ធនឹងការធានានូវការថ្លឹង និងវាស់វាល់ដ៏ជាក់លាក់ និងអាចទុកចិត្តបាន។ មាត្រាសាស្ត្រជាផ្នែកមួយដ៏សំខាន់នៃហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ (Quality Infrastructure) ជាមួយនឹងសមាសធាតុដ៏ទៃទៀត ដែលរួមមាន៖ ស្តង់ដារ ការធ្វើតេស្ត វិញ្ញាបនបត្រកម្ម និងការវាយតម្លៃទទួលស្គាល់[1]។ សហគ្រាសដែលមានសមត្ថភាពក្នុងការបង្ហាញនូវគុណភាព និងសុវត្ថិភាពនៃផលិតផលនិងសេវាកម្ម និងអនុលោមតាមស្តង់ដារអន្តរជាតិ គឺមានភាពចាំបាច់ក្នុងការចូលទៅកាន់ទីផ្សារនាំចេញដែលខ្លួនប្រាថ្នាចូលរួម[2] ដែលប្រការនេះនឹងជួយជំរុញដល់ការលូតលាស់នៃសេដ្ឋកិច្ចជាតិ។

វិស័យមាត្រាសាស្ត្រកម្ពុជា បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់វិស័យឧស្សាហកម្ម និងសកម្មភាពពាណិជ្ជកម្មនៅកម្ពុជា ដោយបង្កឱ្យមានការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ មានភាពត្រឹមត្រូវ សុច្ចរិត ធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពទំនិញ ផលិតផល សេវាកម្ម និងការគ្រប់គ្រង ធានាឱ្យការធ្វើពាណិជ្ជកម្មមានភាពយុត្តិធម៌និងត្រឹមត្រូវ ដែលជួយការពារផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ផលិតផល ទំនិញ និងសេវាកម្ម និងការការពារសុខភាព សុវត្ថិភាព បរិស្ថាន តាមរយៈការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រប្រកបដោយការជឿជាក់ និងទំនុកចិត្ត។ មាត្រាសាស្ត្រនឹងជួយបំពេញនូវតម្រូវការទាមទាររបស់អ្នកទិញទាក់ទងនឹងស្តង់ដារគុណភាព ដែលប្រការនេះ នឹងជួយបង្កើនសមត្ថភាពប្រកួតប្រជែង នៃការធ្វើពាណិជ្ជកម្មនៅលើទីផ្សារជាតិ និងអន្តរជាតិ។

ដោយយល់ឃើញពីសារប្រយោជន៍នៃមាត្រាសាស្ត្រ រាជរដ្ឋាភិបាលកម្ពុជា បានរំលេចពីការរួមចំណែករបស់វិស័យនេះ ទៅលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេសវិស័យឧស្សាហកម្ម។ គោលដៅទី៨ នៃ**គោលនយោបាយអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា** សំដៅ "ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន មានមុខរបរពេញលេញ និងផលិតភាព"[3] ដែលគោលដៅនេះជាផលប៉ះពាល់យូរអង្វែង និងជាការរួមចំណែកដោយវិស័យមាត្រាសាស្ត្រ។ វិស័យមាត្រាសាស្ត្ររួមចំណែកដល់ **យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល**[4] ពាក់ព័ន្ធនឹង៖ ចតុកោណទី៣ មុំទី២ - ការលើកស្ទួយសហគ្រាសធុនតូច មធ្យម និងសហគ្រិនភាព (តភ្ជាប់សហគ្រាសធុនតូច និងមធ្យមជាមួយនឹង ក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស និងជំរុញការនាំចេញផលិតផល ដែលមានសក្តានុពល ជាពិសេសក្នុងវិស័យកសិកម្ម កែច្នៃម្ហូបអាហារ និងកសិឧស្សាហកម្ម) និងចតុកោណទី៣ មុំទី៤ - ការពង្រឹងការប្រកួតប្រជែង(បន្តជំរុញការរៀបចំ និងអនុវត្តស្តង់ដារទំនិញ សេវា និងការគ្រប់គ្រង ហើយលើកកម្ពស់ស្តង់ដារទាំងនេះជាប្រចាំ ដើម្បីជំរុញការចាប់យកបច្ចេកវិទ្យាថ្មី និងលើកកម្ពស់គុណភាព។ រៀបចំយន្តការអនុវត្ត ដើម្បីការពារសិទ្ធិនិងសុវត្ថិភាពអ្នកប្រើប្រាស់ លើកកម្ពស់សុខភាព ពង្រឹងស្តង់ដារទំនិញ និងសេវា ព្រមទាំងលើកកម្ពស់ការប្រកួតប្រជែង)។ ចំណុចទាំងនេះ ត្រូវបានរាជរដ្ឋាភិបាលបញ្ចូលទៅក្នុង**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**[5] ក្នុងជំពូកទី២ - គោលនយោបាយ និងសកម្មភាពអាទិភាព ២០១៩-២០២៣ ត្រង់ចំណុចទី៥ - ការអភិវឌ្ឍវិស័យឯកជន និងការងារ (ចំណុច ៥.២. ការលើកស្ទួយសហគ្រាសធុនតូច មធ្យម និងសហគ្រិនភាព - អាទិភាពទី២ ការផ្សព្វផ្សាយ និងបញ្ជ្រាបបច្ចេកវិទ្យាថ្មី និងការបន្តខិតខំស្វែងរក និងជ្រៀតចូលទីផ្សារនាំចេញសម្រាប់ផលិតផលកម្ពុជា អាទិភាពទី៥ ពង្រឹង និងពង្រីកបន្ថែមការវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចជាមន្ទីរពិសោធន៍ថ្នាក់ជាតិ អាទិភាពទី៦ ជំរុញលើកកម្ពស់

[1] PTB – A National Quality Infrastructure, 2007, page 15

[2] World Bank Group: Role of Quality Infrastructure in Economic Development, 2018, page 4

[3] គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០

[4] រាជរដ្ឋាភិបាលកម្ពុជា - យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤, ២០១៨

[5] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

ផលិតផលនៃសហគ្រាសធុនតូច និងមធ្យម តាមរយៈការពង្រឹងអនុលោមភាព លក្ខខណ្ឌ អនាម័យ និងស្តង់ដារ...) (ចំណុច៥.៤.ការពង្រឹងការប្រកួតប្រជែង - អាទិភាពទី៤ បន្តជំរុញការរៀបចំ និងអនុវត្តស្តង់ដារទំនិញ សេវា និងការគ្រប់គ្រង ហើយលើកកម្ពស់ស្តង់ដារទាំងនេះជាប្រចាំ ដើម្បីជំរុញការចាប់យកបច្ចេកវិទ្យាថ្មី និងលើកកម្ពស់គុណភាព)។

នៅលំដាប់វិស័យ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា** ក្នុងគោលបំណងជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ទៅនឹងខ្សែសង្វាក់តម្លៃសកល សមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើប ដែលផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង[៦]។ សសរស្តម្ភទី៣ នៃគោលនយោបាយនេះ ត្រង់ចំណុច ៦.៣.ខ.សំដៅការកែលម្អបរិស្ថាននិយ័តកម្ម ដែលក្នុងនោះរួមមាន បន្តពង្រឹងក្របខណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រងមាត្រាសាស្ត្រ និងស្តង់ដារ ដែលជាគ្រឹះសម្រាប់សកម្មភាពឧស្សាហកម្ម និងខិតខំប្រឹងប្រែងរៀបចំក្របខណ្ឌគតិយុត្តិ និងការទទួលស្គាល់ជាអន្តរជាតិនូវស្ថាប័នជាតិសំខាន់ៗរួមមាន មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងវិទ្យាស្ថានស្តង់ដារកម្ពុជា ជួយគាំទ្រលើកកម្ពស់សមត្ថភាព និងសមត្ថកិច្ចមាត្រាសាស្ត្រ និងស្តង់ដារ ក្នុងការធានានូវបរិមាណ គុណភាព សុវត្ថិភាព សេវាកម្ម បរិស្ថាន និងការគ្រប់គ្រង និងចាត់វិធានការណ៍ដាក់ស្តែងក្នុងការពង្រឹងការអនុវត្តស្តង់ដារ មាត្រាសាស្ត្រ និងកម្មសិទ្ធឧស្សាហកម្ម ដើម្បីប្រែក្លាយក្របខណ្ឌទាំងនេះ ឱ្យក្លាយជាឧបករណ៍សម្រាប់ជំរុញការប្រកួតប្រជែង។

បច្ចុប្បន្ន **គោលនយោបាយជាតិស្តីពីគុណភាព ២០២២-២០៣០** កំពុងស្ថិតក្នុងសេចក្តីព្រាង ដែលក្នុងនោះមាត្រាសាស្ត្រជាផ្នែកដ៏សំខាន់មួយ នៃហេដ្ឋារចនាសម្ព័ន្ធគុណភាពថ្នាក់ជាតិ ផ្តល់សេវាព្យាសកម្មដែលត្រឹមត្រូវ និងអាចទុកចិត្តបាន ស្របតាមនិយាមមាត្រាសាស្ត្រដែលទទួលស្គាល់ជាអន្តរជាតិ។

ជារួម យើងសង្កេតឃើញថាតួនាទីមាត្រាសាស្ត្របាននិងកំពុងគាំទ្រ និងរួមចំណែកយ៉ាងសំខាន់ដល់យុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា (រួមមាន គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា និងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ) ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

## ១.២. ប្រវត្តិ និងតួនាទី របស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

កន្លងមកវិស័យមាត្រាសាស្ត្រនៅកម្ពុជា ត្រូវបានមើលឃើញថា មានការអភិវឌ្ឍយឺតនៅឡើយ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក។ ប្រការនេះបណ្តាលមកពីកង្វះខាតនៃស្ថាប័នជាតិ ដែលមានសមត្ថភាពទទួលខុសត្រូវ លើការងារមាត្រាសាស្ត្រ។ នៅឆ្នាំ១៩៩២ ប្រទេសកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ហើយកម្ពុជាតម្រូវឱ្យមានការឆ្លើយតបនឹងបទប្បញ្ញត្តិ និងស្តង់ដារមាត្រាសាស្ត្រដែលទទួលស្គាល់ជាអន្តរជាតិ ដើម្បីអាចជ្រៀតចូលក្នុងទីផ្សារអន្តរជាតិ ហើយទាញយកផលប្រយោជន៍ពីសមាជិកភាពរបស់អង្គការនេះ។ ការងារមាត្រាសាស្ត្រ ត្រូវបានរាជរដ្ឋាភិបាលមើលឃើញថាមានសារសំខាន់ ហើយនៅឆ្នាំ១៩៩៥ អង្គភាពវង្វាស់វង្វាល់ (មានឋានៈស្មើនឹងការិយាល័យ) ត្រូវបានបង្កើតឡើងក្នុងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីអនុវត្តការងារមាត្រាសាស្ត្រ ឆ្លើយតបនឹងតម្រូវការទាមទាររបស់ទីផ្សារអន្តរជាតិ។ ដោយតួនាទី និងការទទួលខុសត្រូវលើការងារមាត្រាសាស្ត្រមានការកើនឡើង នៅឆ្នាំ២០០៤ រាជរដ្ឋាភិបាលបានសម្រេចតម្លើងតួនាទី អង្គភាពវង្វាស់វង្វាល់ ទៅជានាយកដ្ឋានមាត្រាសាស្ត្រ ចំណុះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

---

[៦] គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥

នៅឆ្នាំ២០០៩ ច្បាប់ស្តីពីមាត្រាសាស្ត្រ ត្រូវបានប្រកាសឱ្យប្រើ ដែលមានគោលដៅកំណត់អំពីយន្តការ និងវិធានគ្រប់គ្រងមាត្រាសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះបានបញ្ជាក់ច្បាស់ពីគោលបំណង (ឬ សារសំខាន់) នៃមាត្រាសាស្ត្រ និងចំណុចសំខាន់ៗទាក់ទងនឹងការគ្រប់គ្រង និងប្រើប្រាស់មាត្រាសាស្ត្រនៅកម្ពុជា។ ច្បាប់ស្តីពីមាត្រាសាស្ត្របានផ្តល់សិទ្ធិដល់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) ក្នុងការគ្រប់គ្រងរាល់សកម្មភាព និងសេវាកម្មពាក់ព័ន្ធនឹងការងារមាត្រាសាស្ត្រជាអាទិ៍ វិទ្យាសាស្ត្រមាត្រាសាស្ត្រ មាត្រាសាស្ត្រឧស្សាហកម្ម និងនីត្យានុកូលមាត្រាសាស្ត្រស្របតាមគោលនយោបាយជាតិផ្នែកមាត្រាសាស្ត្រ[7]។

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១១ ស្របតាមច្បាប់ស្តីពីមាត្រាសាស្ត្រ។ នៅឆ្នាំ២០២០ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានប្តូរឈ្មោះទៅជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ហើយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបានបង្កើតឡើង[8]។ យោងតាមមាត្រា ៤ និងមាត្រា ២៩ នៃអនុក្រឹត្យនេះ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវបានបង្កើតឡើងជាអង្គភាពថ្នាក់ជាតិ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលមានឋានៈស្មើនឹងអគ្គនាយកដ្ឋាន។

តួនាទី និងភារកិច្ចរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវបានចែងក្នុងមាត្រា ២៩ នៃអនុក្រឹត្យខាងលើនេះ ដែលមានដូចជា រៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសម្រាប់អភិវឌ្ឍន៍ផ្នែកមាត្រាសាស្ត្រ គ្រប់គ្រង និងអនុវត្តរាល់ការងារមាត្រាសាស្ត្រ (រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ព្យាសកម្ម ត្រួតពិនិត្យផ្ទៀងផ្ទាត់ ធ្វើតេស្ត វិភាគ និងអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រ) កសាងសមត្ថភាពធនធានមនុស្ស សហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ។ល។ (សូមមើលសេចក្តីលម្អិតក្នុងអនុក្រឹត្យលេខ ៤៨ អនក្រ.បក/២០២០)។

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិបំពេញមុខងារ និងផ្តល់សេវាកម្មមាត្រាសាស្ត្រនានា ដែលគាំទ្រដល់ការអភិវឌ្ឍបណ្តាវិស័យ ដូចខាងក្រោម៖

១- វិស័យឧស្សាហកម្ម
២- វិស័យសហគ្រាសធុនតូច និងមធ្យម
៣- វិស័យសុខភាពសាធារណៈ
៤- វិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
៥- វិស័យសាធារណៈការ និងដឹកជញ្ជូន
៦- ពាណិជ្ជកម្ម និងសេវាកម្ម
៧- វិស័យអគ្គិសនី ឧស្ម័ន និងទឹកស្អាត
៨- សេវាកម្មប្រៃសណីយ៍ វិស្វកម្ម និងវិស័យផ្សេងទៀត។

អនុក្រឹត្យខាងលើនេះដែរបានចែងពីរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដែលមាននាយកដ្ឋានចំនួន ៤(បួន) ក្រោមឱវាទ ហើយតួនាទី និងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ ត្រូវបានចែងក្នុងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីមួយៗ (ប្រកាសលេខ ១៤១ ១៤២ ១៤៣ និង ១៤៤ MISTI/2020)។ នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ និងនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ ជានាយកដ្ឋានកម្មវិធី ដែលមានតួនាទីស្នូលក្នុងការផ្តល់សេវាកម្មមាត្រាសាស្ត្រ នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម ជានាយកដ្ឋានគាំទ្រកម្មវិធី ដោយ

[7] ច្បាប់ស្តីពីមាត្រាសាស្ត្រ ២០០៩ មាត្រា ៥

[8] អនុក្រឹត្យលេខ ៤៨ អនក្រ.បក/២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

បំពេញតួនាទីនានា ដែលគាំទ្រដោយផ្ទាល់ ដល់កម្មវិធី និងផ្តល់សេវាកម្មមាត្រាសាស្ត្រ និងចំណែកនាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ (និងការិយាល័យច្រកចេញចូលតែមួយ) ជានាយកដ្ឋានផ្តល់ការគាំទ្រទូទៅដល់ ម.ម.ជ ទាំងមូល[៩]។

នៅថ្នាក់ក្រោមជាតិ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមានការិយាល័យមាត្រាសាស្ត្រ នៅ ២៥ មន្ទីរ ឧ.វ.ប.ន រាជធានី-ខេត្ត សម្រាប់អនុវត្តការងារមាត្រាសាស្ត្រ ដោយផ្ទាល់នៅតាមមូលដ្ឋានរបស់ខ្លួន។ បច្ចុប្បន្ន ថ្នាក់ជាតិមិនទាន់អាចធ្វើប្រតិភូកម្មការងារមាត្រាសាស្ត្រ ទៅថ្នាក់ក្រោមជាតិបានច្រើននៅឡើយ ដោយសារកត្តាសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិនៅមានកម្រិត និងកង្វះខាតឧបករណ៍ បរិក្ខា និងស្តង់ដារមាត្រាសាស្ត្រ។

## ១.៣. ភាពចាំបាច់ និងដំណើរការអភិវឌ្ឍយុទ្ធសាស្ត្រមាត្រាសាស្ត្រ

តួនាទីនៃមាត្រាសាស្ត្រនៅកម្ពុជាកាន់តែមានសារសំខាន់ និងត្រូវបានទទួលស្គាល់កាន់តែច្រើន។ ការវាស់វាល់ត្រឹមត្រូវពិតជាមានសារសំខាន់ ដែលនាំនូវលទ្ធផលផលិតកម្មត្រឹមត្រូវ លើកកម្ពស់គុណភាពផលិតកម្ម ឈានទៅបង្កើនសមត្ថភាពប្រកួតប្រជែងលើទីផ្សារ តាមរយៈការឆ្លើយតបនឹងតម្រូវការរបស់អ្នកទិញ ដោយអនុលោមតាមស្តង់ដារ ឬ លក្ខខណ្ឌសម្រាប់ការវាយតម្លៃទទួលស្គាល់ (Accreditation)។ បច្ចុប្បន្ននេះ តម្រូវការសេវាកម្មមាត្រាសាស្ត្រត្រូវបានមើលឃើញថាមានការកើនឡើង ដោយផ្អែកលើការកើនឡើងនៃតម្រូវការ នៃការធ្វើពាណិជ្ជកម្ម ទៅទីផ្សារអន្តរជាតិ (ជាមួយប្រទេសឧស្សាហកម្ម) ដែលពឹងផ្អែកយ៉ាងខ្លាំងលើស្តង់ដារ និងក្របខណ្ឌបច្ចេកទេស។ ហេតុនេះ សេវាកម្មមាត្រាសាស្ត្រនៅកម្ពុជា ដែលមានកម្រិតនៅឡើយ (ទាំងប្រភេទ និងទំហំនៃលទ្ធភាពផ្តល់សេវា) តម្រូវឱ្យមានការអភិវឌ្ឍបន្ថែមទៀត ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងទាំងឡាយ។ ប្រការនេះ តម្រូវឱ្យមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដែលជាប្រតិបត្តិករជាតិលើការងារមាត្រាសាស្ត្រ ពិចារណាអំពីទិសដៅ និងយុទ្ធសាស្ត្រច្បាស់លាស់ ក្នុងការអភិវឌ្ឍវិស័យមាត្រាសាស្ត្រនៅកម្ពុជាឱ្យមានភាពរីកចម្រើន សមស្របតាមស្ថានភាព និងបរិបទ របស់ប្រទេសកម្ពុជា និងបរិបទមាត្រាសាស្ត្រពិភពលោក។

អាស្រ័យហេតុនេះ ការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់វិស័យមាត្រាសាស្ត្រនៅកម្ពុជា ពិតជាមានភាពចាំបាច់ ក្នុងការបង្កើតឱ្យបានជាផែនការយុទ្ធសាស្ត្រមួយ សម្រាប់ធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់ប្រតិបត្តិ និងកៀរគរកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ នឹងជួយឱ្យស្ថាប័នប្រតិបត្តិករមាត្រាសាស្ត្រជាតិនិងអ្នកពាក់ព័ន្ធ គាំទ្រនិងអនុវត្តការងារមាត្រាសាស្ត្រមានលក្ខណៈជាប់លាប់ សង្គតិភាព និងប្រសិទ្ធភាព។

ដំណើរការអភិវឌ្ឍយុទ្ធសាស្ត្រ ធ្វើឡើងដោយមានការចូលរួមពីមន្ត្រី ថ្នាក់ដឹកនាំសំខាន់ៗ របស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងអ្នកពាក់ព័ន្ធ ក្រោមការជួយសម្របសម្រួលពីទីប្រឹក្សា ២ រូប មកពីវិទ្យាស្ថានមាត្រាសាស្ត្រជាតិអាល្លឺម៉ង់ (PTB)។ ក្រុមការងារមួយ ដែលមានសមាជិកចំនួន ១៥ រូប (ថ្នាក់ដឹកនាំ និងមន្ត្រី ម.ម.ជ ចំនួន ១២ រូប និងទីប្រឹក្សារបស់ PTB ចំនួន ៤ រូប) ដែលអនុម័តទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងត្រូវបានបង្កើតឡើងសម្រាប់ដឹកនាំ និងសម្របសម្រួលដំណើរការកសាងយុទ្ធសាស្ត្រទាំងមូល។ លើសពីនេះ ក្រុមការងារស្នូលផ្ទៃក្នុង ម.ម.ជ ចំនួន ២០ នាក់ ត្រូវបានបង្កើតឡើង ដែលមានសមាសភាពមកពីគ្រប់នាយកដ្ឋាន (និងការិយាល័យ) ទាំងអស់ ចំណុះ ម.ម.ជ ហើយក្រុមស្នូលនេះ មានតួនាទីចូលរួមយ៉ាងសកម្មក្នុងដំណើរការកសាងយុទ្ធសាស្ត្រ ប្រកបដោយភាពជាម្ចាស់ការខ្ពស់។ ដំណើរការកសាងយុទ្ធសាស្ត្រវិស័យមាត្រាសាស្ត្រទាំងមូល ធ្វើឡើងជា ៦(ប្រាំមួយ) ជំហាន ដូចខាងក្រោម៖

---

[៩] ដោយសារមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) ជារចនាសម្ព័ន្ធមួយរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដូច្នេះ ម.ម.ជ មិនមាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដូចស្ថាប័ន(ស្វយ័ត)ដទៃទៀយ ពោលគឺមាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ បានដើរតួនាទីជានាយកដ្ឋានគាំទ្រទូទៅ។

| ជំហាន | កិច្ចការ |
|---|---|
| ១ | ត្រៀមរៀបចំ ប្រជុំតម្រង់ទិស ពិភាក្សាអំពីដំណើរការ និងការទទួលខុសត្រូវ |
| ២ | បង្កើនការយល់ដឹងអំពីការកសាងយុទ្ធសាស្ត្រ តាមរយៈវគ្គបណ្តុះបណ្តាលរយៈពេល ២ ថ្ងៃ ពេញ |
| ៣ | ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ[10] |
| ៤ | សិក្ខាសាលាលើកយុទ្ធសាស្ត្រ ចំនួន ៤ ថ្ងៃ ពេញ ចូលរួមដោយក្រុមការងារស្នូល ២០ រូប |
| ៥ | ប្រជុំតាមនាយកដ្ឋាននីមួយៗ បញ្ជាក់ពីគោលដៅ ជំពូកការងារ ដែលរួមចំណែកទៅយុទ្ធសាស្ត្រ |
| ៦ | សរសេរសេចក្តីព្រាងផែនការ ដើម្បីដាក់ជូនថ្នាក់ដឹកនាំ ម.ម.ជ ពិនិត្យ និងបញ្ជូនអនុម័ត |

ក្រុមការងារ ម.ម.ជ ក្រោមការជួយផ្តល់ឱវាទពីទីប្រឹក្សាវិទ្យាស្ថានមាត្រាសាស្ត្រជាតិអាល្លឺម៉ង់ (PTB) បានប្រមូលផ្តុំចូល លទ្ធផលប្រជុំ និងលទ្ធផលពីសិក្ខាសាលាទាំងអស់ ដាក់ចូលទៅក្នុងទម្រង់មួយ ជាសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ។ សេចក្តីព្រាងនេះ ត្រូវបានពិនិត្យឡើងវិញ ដោយក្រុមការងារ ម.ម.ជ បន្ទាប់មក ត្រួតពិនិត្យដោយថ្នាក់ដឹកនាំ ម.ម.ជ ក្លាយទៅជាសេចក្តីព្រាងចុងក្រោយ។ ទីបញ្ចប់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ ត្រូវបានអនុម័តដោយ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## ១.៤. ចក្ខុវិស័យ បេសកកម្ម គោលដៅ និងគុណតម្លៃ

### ១.៤.១. ចក្ខុវិស័យ

**ចក្ខុវិស័យសម្រាប់វិស័យមាត្រាសាស្ត្រ**

វិស័យមាត្រាសាស្ត្រនៅកម្ពុជាត្រូវបានអភិវឌ្ឍយ៉ាងល្អ ក្នុងការលើកកម្ពស់គុណភាពនៃផលិតកម្ម ធានាដល់ការធ្វើពាណិជ្ជកម្មប្រកបដោយយុត្តិធម៌ និងប្រកួតប្រជែង ដើម្បីរួមចំណែកដល់ការលូតលាស់សេដ្ឋកិច្ចជាតិ។

ក្នុងបរិបទផលិតកម្ម មាត្រាសាស្ត្រជួយដល់សហគ្រាស អាចផលិតទំនិញបានកាន់តែមានភាពសុក្រឹតកាន់តែរហ័ស និងស្របតាមនិយាម (ស្តង់ដារ) កាន់តែខ្ពស់ ដែលធ្វើឱ្យអ្នកប្រើប្រាស់អាចរកទំនិញដែលមានគុណភាពខ្ពស់។ ប្រការនេះបានគាំទ្រដល់ការលើកកម្ពស់ភាពប្រកួតប្រជែងនៃផលិតផលរបស់សហគ្រាស ទៅលើទីផ្សារអន្តរជាតិ ដែលជាទូទៅតម្រូវឱ្យមានស្តង់ដារ និងគុណភាព។ ក្នុងបរិបទពាណិជ្ជកម្ម (ជាតិ និងអន្តរជាតិ) មាត្រាសាស្ត្រ (នីត្យានុកូលមាត្រាសាស្ត្រ) បានបំពេញតួនាទីក្នុងការធានាភាពត្រឹមត្រូវដល់ឧបករណ៍វាស់វាល់ សម្រាប់ការការពារសុខភាពសាធារណៈ សុវត្ថិភាព បរិស្ថាន ការពារអ្នកប្រើប្រាស់ និងធានាយុត្តិធម៌ក្នុងការធ្វើពាណិជ្ជកម្ម។

**ចក្ខុវិស័យសម្រាប់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ)**

**ម.ម.ជ** ជាអង្គភាពជាតិទទួលបន្ទុកការងារមាត្រាសាស្ត្រ ប្រកបដោយឧត្តមភាពឈានមុខរបស់ប្រទេសកម្ពុជា ដែលមានការទទួលស្គាល់សមត្ថភាពជាអន្តរជាតិ។

[10] មានអ្នកពាក់ព័ន្ធចំនួន ២៧ រូប ដែលបានផ្តល់យោបល់អំពីស្ថានភាពបច្ចុប្បន្ន និងទិសដៅអនាគតរបស់ ម.ម.ជ ក្នុងនោះមាន៖ ថ្នាក់ដឹកនាំ ម.ម.ជ (១១ រូប) អតិថិជន ឬ អង្គភាពប្រើប្រាស់សេវាមាត្រាសាស្ត្រ (៩ ក្រុមហ៊ុន/អង្គភាព) MISTI (៤ រូប) អ្នកធ្វើគោលនយោបាយ (១ អង្គភាព) ដៃគូអភិវឌ្ឍន៍ (២ស្ថាប័ន)

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) គឺជាអង្គភាពជាតិតែមួយគត់នៅកម្ពុជា ដែលគ្រប់គ្រងរាល់សកម្មភាព និងសេវាកម្មពាក់ព័ន្ធនឹងការងារមាត្រាសាស្ត្រ ស្របតាមច្បាប់ស្តីពីមាត្រាសាស្ត្រ។ ក្នុងបរិបទមាត្រាសាស្ត្រ ម.ម.ជ មិនអាចប្រតិបត្តិការដាច់ដោយឡែកពីមាត្រាសាស្ត្រពិភពលោកបានឡើយ ពោលគឺ ម.ម.ជ តម្រូវឱ្យមានការទទួលស្គាល់ជាសកល និងជាផ្នែកមួយនៃប្រព័ន្ធមាត្រាសាស្ត្រអន្តរជាតិ សម្រាប់ធានាការប្រៀបធៀបបាន (Comparability) នៃសមត្ថភាពវង្វាស់វង្វាល់ និងស្តង់ដារ។

### ១.៤.២. បេសកកម្ម

បេសកកម្មរបស់ ម.ម.ជ គឺផ្តល់សេវាកម្មមាត្រាសាស្ត្រគ្រប់ប្រភេទ ដល់វិស័យពាណិជ្ជកម្ម ឧស្សាហកម្ម និងវិស័យផ្សេងទៀត ទៅតាមនិយាមដែលទទួលស្គាល់ដោយអន្តរជាតិ ដើម្បីធានាសុក្រឹតភាពនៃទម្ងន់ និងរង្វាស់រង្វាល់ សំដៅលើកកម្ពស់សុខភាព សុវត្ថិភាព និងបរិស្ថាន។

សម្គាល់៖ សេវាកម្មមាត្រាសាស្ត្រគ្រប់ប្រភេទ រួមមាន៖ សេវាព្យាសកម្ម ត្រួតពិនិត្យផ្ទៀងផ្ទាត់ អនុម័តគំរូ ការបណ្តុះបណ្តាល ការពិគ្រោះយោបល់ ការផ្តល់សេវាផ្សេងទៀតពាក់ព័ន្ធនឹងការងារមាត្រាសាស្ត្រ និងការសម្របសម្រួលសេវាទៅស្ថាប័នមាត្រាសាស្ត្រថ្នាក់តំបន់ និងអន្តរជាតិ។

### ១.៤.៣. គោលដៅ

ដើម្បីសម្រេចបានចក្ខុវិស័យ និងបេសកកម្មខាងលើ ម.ម.ជ បានកំណត់គោលដៅសំខាន់ៗ ចំនួន ៥ (ប្រាំ) ដូចខាងក្រោម៖

១- លើកកម្ពស់ និងពង្រីកសេវាកម្មមាត្រាសាស្ត្រ ដែលជួយគាំទ្រទីផ្សារ
២- ពង្រឹងការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ
៣- ធ្វើសុខដុមនីយកម្ម និងសមាហរណកម្មការងារមាត្រាសាស្ត្រ
៤- លើកកម្ពស់ការយល់ដឹងរបស់អ្នកពាក់ព័ន្ធអំពីមាត្រាសាស្ត្រ និង
៥- បន្តអភិវឌ្ឍសមត្ថភាព និងពង្រឹងមុខងារគាំទ្រទូទៅ។

### ១.៤.៤. គុណតម្លៃស្នូល

គុណតម្លៃ ជាជំនឿ ដែលមន្ត្រី និងថ្នាក់ដឹកនាំទាំងអស់របស់ ម.ម.ជ ប្រកាន់យកជារួម ក្នុងការប្រតិបត្តិការងារមាត្រាសាស្ត្ររបស់ខ្លួន។ ជំនឿទាំងនេះនឹងជំរុញឱ្យមានជាឥរិយាបថ ឬ ការប្រព្រឹត្តស្របគ្នា ក្នុងចំណោមមន្ត្រីទាំងអស់ ដែលនាំឱ្យមានការលើកកម្ពស់ការងារក្រុម ផលិតភាព និងប្រសិទ្ធភាពការងារ។

១- ការថ្លឹង និងវាស់វាល់ត្រឹមត្រូវ ធានាសុក្រឹតភាព
២- ការងារមាត្រាសាស្ត្រដែលមានការទទួលស្គាល់ នាំឱ្យមានទំនុកចិត្ត
៣- ការងារក្រុមនិងកិច្ចសហការ នាំឱ្យយើងសម្រេចប្រកបដោយប្រសិទ្ធភាព និង
៤- ក្រមសីលធម៌វិជ្ជាជីវៈ និងការទទួលខុសត្រូវ។

# ជំពូកទី២៖ បរិបទ និងស្ថានភាពនៃវិស័យមាត្រាសាស្ត្រ

## ២.១. បរិបទនៃមាត្រាសាស្ត្រពិភពលោក

### ២.១.១. មាត្រាសាស្ត្រជាអ្វី?

មាត្រាសាស្ត្រ (Metrology) សំដៅលើវិទ្យាសាស្ត្រនៃទម្ងន់ និងរង្វាស់រង្វាល់ និងការប្រើប្រាស់របស់វា[11]។ និយាយយ៉ាងសាមញ្ញ មាត្រាសាស្ត្រ គឺជាវិទ្យាសាស្ត្រនៃការថ្លឹង និងវាស់វាល់ដោយសុក្រឹត និងជាទីទុកចិត្ត។ មាត្រាសាស្ត្ររួមបញ្ចូលរាល់ផ្នែកទ្រឹស្តី និងការអនុវត្ត ដែលទាក់ទងនឹងទម្ងន់ និងរង្វាស់រង្វាល់ មិនថាឡើយពីកម្រិតមិនពិតប្រាកដនៃរង្វាស់រង្វាល់ (Measurement Uncertainty) និងដែននៃការអនុវត្ត។ មាត្រាសាស្ត្រជាវិទ្យាសាស្ត្រនៃទម្ងន់ និងរង្វាស់រង្វាល់ រួមមានការកំណត់និយមន័យនៃឯកតាមាត្រាសាស្ត្រ សមិទ្ធិកម្មនៃស្តង់ដាមាត្រាសាស្ត្រ ការបង្កើតឧបករណ៍មាត្រាសាស្ត្រនិងវិសាលភាពនៃការប្រើប្រាស់ ការបង្កើតខ្សែសង្វាក់ប្រព័ន្ធដានមាត្រាសាស្ត្រ (Traceability Chain) នៃលទ្ធផលរង្វាស់រង្វាល់ (Measrurement Result) ក៏ដូចជាការងារដ៏ទៃទៀតពាក់ព័ន្ធនឹងការថ្លឹង និងវាស់វាល់[12]។ មាត្រាសាស្ត្រមានន័យបែបទូលំទូលាយ ពីព្រោះមានវត្ថុជាច្រើនដែលអាចថ្លឹង និងវាស់វាល់បាន និងមានវិធីជាច្រើនសម្រាប់ថ្លឹង និងវាស់វាល់ ក៏ដូចជាមានវិធីជាច្រើនសម្រាប់បង្ហាញលទ្ធផលរង្វាស់រង្វាល់ (Measrurement Result)។ ការប្រើប្រាស់មាត្រាសាស្ត្របានគាំទ្រដល់គុណភាពនៃការផលិតទំនិញ និងដំណើរការនានា តាមរយៈការផ្តល់រង្វាស់រង្វាល់ ដែលមានភាពសុក្រឹត និងអាចទុកចិត្តបាន។

ការងារមាត្រាសាស្ត្រ រួមមានសកម្មភាព ៣ សំខាន់ៗ[13]៖

១- ការកំណត់និយមន័យ នៃឯកតាមាត្រាសាស្ត្រ ដែលទទួលស្គាល់ជាអន្តរជាតិ (ឧ. ឯកតាម៉ែត្រ)

២- សមិទ្ធិកម្មនៃឯកតាមាត្រាសាស្ត្រ ដោយវិធីសាស្ត្របែបវិទ្យាសាស្ត្រ (ឧ. សមិទ្ធិកម្មនៃ ឯកតាម៉ែត្រតាមរយៈការប្រើប្រាស់ ឡាស៊ែរ)

៣- ការបង្កើតខ្សែសង្វាក់ប្រព័ន្ធដានមាត្រាសាស្ត្រ (Traceability Chain) តាមរយៈការកំណត់ និងកត់ត្រាជាឯកសារ នូវតម្លៃ និងភាពសុក្រឹតនៃការថ្លឹង និងវាស់វាល់ និងការផ្សាយចំណេះដឹង (ឧ. ការកត់ត្រាជាឯកសារនូវផលធៀបរវាង វីសមីក្រូម៉ែត្រ នៅក្នុងរោងជាងវិស្វកម្មដ៏ជាក់លាក់មួយ និងនៅក្នុងមន្ទីរពិសោធន៍ថ្នាក់ទីមួយ សម្រាប់រង្វាស់ប្រវែងបែបអុបទិក)។

### ២.១.២. មាត្រាសាស្ត្រជាប្រព័ន្ធ ដែលដំណើរការជាសកល

ការថ្លឹង និងវាស់វាល់ ចាប់មានតាំងពីសង្គមសម័យបុរាណ ដោយសារចំណុចនេះបានធ្វើឱ្យមានការប៉ះពាល់ដល់គ្រប់ផ្នែកនៃជីវិតមនុស្ស។ មានការលើកឡើងថា មនុស្សយើងដំបូងចាប់អារម្មណ៍លើការស្វែងយល់ពីពេលវេលា ដោយមើលបាតុភូតធម្មជាតិ ដែលតែងតែកើតឡើងទៅតាមអំឡុងពេល បន្ទាប់មក ចាប់អារម្មណ៍ពីប្រវែង ដូចជាការចង់ដឹងពីចម្ងាយ។ ទោះបីជាការថ្លឹង និងវាស់វាល់ និងឯកតារង្វាស់រង្វាល់ មានការប្រែប្រួលទៅតាមកាលប្រវត្តិកន្លងមក ក៏គោលដៅនៅតែរក្សាដដែល គឺធ្វើយ៉ាងណាឱ្យការថ្លឹង និងវាស់វាល់មានភាពសុក្រឹត តាមដែលអាចធ្វើទៅបាន។ សហគមន៍មាត្រាសាស្ត្រពិភពលោករំពឹងទុកថា ដោយឈរលើមូលដ្ឋាន នៃការស្រាវជ្រាវ ប្រព័ន្ធឯកតាមាត្រាសាស្ត្រអន្តរជាតិ SI (International System of Unit) នឹងត្រូវបានកំណត់ឡើងវិញនាពេលអនាគត ហើយ

---

[11] BIPM. (2021). *National Metrology Systems – Developing the institutional and Legislation Framework*, page 7

[12] JCGM Member Organizations (BIPM, IEC, IFCC, ILAC, ISO, IUPAC, IUPAP, and OIML). (2012). *JCGM 200:2012 – International Vocabulary of Metrology – Basic and General Concepts and Associated Terms (VIM)*. 3rd Edition, page 16

[13] EURAMET e.V. (2008). *Metrology – In Short*, 3rd Edition, page 9

នេះជាកត្តាចង្អុលបង្ហាញមួយដែលថា មាត្រាសាស្ត្រជាវិទ្យាសាស្ត្រដ៏ស្មុគស្មាញ ដែលជះឥទ្ធិពលលើជីវិតប្រចាំថ្ងៃរបស់យើង។

ការថ្លឹង និងវាស់វាល់ ពិតជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់យើង ហើយលទ្ធផលចេញពីការថ្លឹង និងវាស់វាល់ ប៉ះពាល់ដល់ការធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យជាច្រើន។ ក្រៅពីគោលបំណងការពារអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ក្នុងប្រតិបត្តិការតាមក្របខណ្ឌបញ្ញត្តិ ការថ្លឹង និងវាស់វាល់ជាក់លាក់ទៅលើផ្នែកនានាពាក់ព័ន្ធនឹងគុណភាព បានក្លាយជាចំណុចសំខាន់ សម្រាប់ផលិតផលបែបសកលភាវូបនីយកម្ម ការធ្វើពាណិជ្ជកម្ម និងសេវាកម្ម ជាមួយនឹងក្រុមហ៊ុនអន្តរជាតិ និងអ្នកផ្គត់ផ្គង់ក្នុងស្រុក ទៅទូទាំងពិភពលោក។ ប៉ុន្តែប្រព័ន្ធ និងឯកតាត្រូវតែកំណត់ជាមុនសិន មុននឹងឈានដល់ការថ្លឹង និងវាស់វាល់។ ប្រការនេះ តម្រូវឱ្យមានការធ្វើ សុខដុមនីយកម្ម និងការបង្កើតប្រព័ន្ធដែលមានភាពសមមូល សម្រាប់ទូទាំងពិភពលោក ទាំងបញ្ហាបច្ចេកទេស និងក្របខណ្ឌនយោបាយ។ សុខដុមនីយកម្មនេះ បានចាប់ផ្តើមនៅទីក្រុងប៉ារីស តាំងពីឆ្នាំ ១៨៧៥ ជាមួយនឹង អនុសញ្ញាម៉ែត្រ (Convention of the Metre)[14]។ មាត្រាសាស្ត្រ តម្រូវឱ្យមានការប្រតិបត្តិដែលមនុស្សទូទៅក្នុងពិភពលោកអាចទទួលយកបាន តាមរយៈការចងបណ្តាញ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ការបង្កើតឯកតាមាត្រាសាស្ត្រដូចគ្នា ក៏ដូចជាការទទួលស្គាល់ការវាយតម្លៃទទួលស្គាល់ និងការធ្វើតេស្តដូចគ្នា ទៅលើស្តង់ដារមាត្រាសាស្ត្រ និងមន្ទីរពិសោធន៍ នៅក្នុងប្រទេសផ្សេងៗ។

ស្ថាប័នមាត្រាសាស្ត្រអន្តរជាតិសំខាន់ៗ បាននិងកំពុងដើរតួយ៉ាងសំខាន់ ក្នុងសមាហរណកម្ម និងសុខដុមនីយកម្មការងារមាត្រាសាស្ត្រ សម្រាប់ទូទាំងពិភពលោក តាមរយៈការកៀរគរសមាជិកពីបណ្តាប្រទេសនានា ដើម្បីលើកកម្ពស់នៃការប្រតិបត្តិជាសមូហភាពនូវការងារមាត្រាសាស្ត្រ។ ស្ថាប័នទាំងនេះរួមមាន៖

១- ការិយាល័យអន្តរជាតិទម្ងន់និងរង្វាស់រង្វាល់ (BIPM) - ត្រូវបានបង្កើតឡើងក្រោមអនុសញ្ញាម៉ែត្រ ដែលជាអង្គការអន្តររដ្ឋាភិបាល គ្រប់គ្រងដោយមហាសន្និបាតទម្ងន់និងរង្វាស់រង្វាល់ (CGPM)។ អង្គការ BIPM មានបេសកកម្មធ្វើការជាមួយវិទ្យាស្ថានមាត្រាសាស្ត្រជាតិ (NMIs) នៃរដ្ឋជាសមាជិកអង្គការមាត្រាសាស្ត្រតំបន់ (RMOs) និងដៃគូយុទ្ធសាស្ត្រនៅទូទាំងពិភពលោក ដោយមិនលំអៀង ដើម្បីលើកកម្ពស់ និងជំរុញដល់ការប្រៀបធៀបជាសកលនៃរង្វាស់រង្វាល់។

២- អង្គការនីត្យានុកូលមាត្រាសាស្ត្រអន្តរជាតិ (OIML) - មានបេសកកម្មគាំទ្រឱ្យប្រទេសនានាមានហេដ្ឋារចនាសម្ព័ន្ធនីត្យានុកូលមាត្រាសាស្ត្រ ប្រកបដោយប្រសិទ្ធភាព ដែលមានភាពស្របគ្នា និងទទួលស្គាល់ជាអន្តរជាតិ សម្រាប់គ្រប់វិស័យដែលរដ្ឋាភិបាលមានទំនួលខុសត្រូវ ដូចជាស្ថាប័នដែលជួយសម្របសម្រួលពាណិជ្ជកម្ម បង្កើតទំនុកចិត្តគ្នាទៅវិញទៅមក និងធ្វើឱ្យចុះសម្រុងនឹងកម្រិតការការពារអតិថិជនទូទាំងពិភពលោក។

៣- អង្គការកម្មវិធីមាត្រាសាស្ត្រអាស៊ីប៉ាស៊ីហ្វិក (APMP) - ជាក្រុមនៃវិទ្យាស្ថានមាត្រាសាស្ត្រជាតិ (NMIs) ដែលមកពីប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពមាត្រាសាស្ត្រ តាមរយៈការចែករំលែកជំនាញ និងផ្លាស់ប្តូរសេវាកម្មបច្ចេកទេស ក្នុងចំណោមមន្ទីរពិសោធន៍សមាជិក។ បេសកកម្មរបស់ APMP លើកកម្ពស់និងគាំទ្រហេដ្ឋារចនាសម្ព័ន្ធទម្ងន់ និងរង្វាស់រង្វាល់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក សំដៅជួយសម្រួលដល់ពាណិជ្ជកម្មអន្តរជាតិ ធ្វើឱ្យប្រសើរឡើងប្រសិទ្ធភាពឧស្សាហកម្ម និងការប្រកួតប្រជែង ធានាឱ្យមានសមធម៌ក្នុងទីផ្សារ និងលើកកម្ពស់គុណភាពជីវិត និងបរិស្ថាន។

ក្រៅពីអង្គការខាងលើ ក៏នៅមានអង្គការវេទិកា ឬ បណ្តាញដទៃមួយចំនួនទៀត ដែលធ្វើការរួមគ្នា លើហេដ្ឋារចនាសម្ព័ន្ធមាត្រាសាស្ត្រ។

[14] Dr. Clemens Sanetra & Rocio M. Marban. (2007). *The Answer to the Global Quality Challenge: A National Quality Infrastructure*, page 60-61

## ២.១.៣. តួនាទី និងសារសំខាន់នៃមាត្រាសាស្ត្រ

ការតាមដានលើការប្រែប្រួលនៃសីតុណ្ហភាព បម្រែបម្រួលអាកាសធាតុ កត់សម្គាល់សកម្មភាពរញ្ជួយដី ការងារតារាសាស្ត្រ ។ល។ មិនអាចទៅរួចដោយមិនមានមាត្រាសាស្ត្រឡើយ។ មាត្រាសាស្ត្របង្ករឱ្យយើងអាចត្រួតពិនិត្យខ្យល់ដែលយើងអាចដកដង្ហើមបាន ទឹកដែលយើងពិសារ អាហារដែលយើងបរិភោគ។ ការថ្លឹង និងវាស់វាល់ត្រឹមត្រូវក៏ធានាបាននូវសុវត្ថិភាព និងប្រសិទ្ធភាពនៃការព្យាបាលផ្នែកវេជ្ជសាស្ត្រ។

មាត្រាសាស្ត្របានដើរតួនាទីយ៉ាងសំខាន់ នៅពេលដែលតម្រូវការសង្គមចង់ឱ្យមានការការពារទាំងអ្នកលក់ និងអ្នកទិញ ក្នុងការផ្លាស់ប្តូរពាណិជ្ជកម្មនៃទំនិញ ឬ សេវាកម្ម ឬ ការប្រើប្រាស់ការថ្លឹង និងវាស់វាល់សម្រាប់ដាក់ទណ្ឌកម្ម ដោយសារស្ទើតែគ្រប់ប្រទេសបានផ្តល់ការការពារបែបនេះ តាមរយៈប្រព័ន្ធគតិយុត្ត។ សេដ្ឋកិច្ចពិភពលោកពឹងផ្អែកលើការថ្លឹង និងវាស់វាល់ ដែលអាចទុកចិត្តបាន ដែលមិនបង្ហាញពី របាំងបច្ចេកទេសសម្រាប់ធ្វើពាណិជ្ជកម្ម។ សមមូលភាពនៃស្តង់ដារ ក៏ដូចជាការបង្ហាញនូវកម្រិតអនុលោម ដែលអាចទទួលយកបាន ជាមួយនិងស្តង់ដារដែលពាក់ព័ន្ធធ្វើឱ្យមានលទ្ធភាពក្នុងការប្រៀបធៀបនៃការថ្លឹង និងវាស់វាល់ដែលធ្វើឡើងនៅតាមបណ្តាលប្រទេសផ្សេងៗ។

ការថ្លឹង និងវាស់វាល់នានាជា គីឡូក្រាម លីត្រ ម៉ែត្រ វ៉ាត់ កម្លាំងសេះ ។ល។ សម្រាប់ធ្វើពាណិជ្ជកម្មមិនអាចទៅរួចដោយគ្មានមាត្រាសាស្ត្រឡើយ។ ជនជាតិក្រិចតាំងពីសម័យបុរាណ បានដឹងយ៉ាងច្បាស់ពីទម្ងន់ និងរង្វាស់រង្វាល់ ដែលប្រើប្រាស់ ដោយជនជាតិមកពីកន្លែងផ្សេងគ្នាដែលមានទំនាក់ទំនងពាណិជ្ជកម្មជាមួយ។ ដើម្បីធ្វើពាណិជ្ជកម្មមានប្រសិទ្ធផលច្រើន ត្រូវមានឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់ក្នុងស្រុក សម្រាប់ថ្លឹង និងវាស់វាល់ ម៉ាស់និងចំណុះលើទីផ្សារ។ ប្រវត្តិសាស្ត្របានប្រាប់យើងថា មានការបង្កើតនូវក្របខណ្ឌច្បាប់ លើការថ្លឹង និងវាស់វាល់ ក៏ដូចជាការប្រកាសនូវស្តង់ដារជាតិទៅតាមអ្នកគ្រប់គ្រងនៃប្រទេសនីមួយៗ។ ការថ្លឹង និងវាស់វាល់ ដែលស្គាល់ពីកម្រិតនៃភាពលំអៀងច្បាស់លាស់ គឺជាមូលដ្ឋាន សម្រាប់គ្រប់គ្រងគុណភាពរបស់ឧស្សាហកម្ម ដែលជំរុញឱ្យមានការកើនឡើងនៃគុណតម្លៃ និងគុណភាពនៃផលិតផល។ ការថ្លឹង និងវាស់វាល់ដែលមានសុក្រឹត និងលើកកម្ពស់ប្រសិទ្ធផលនៃប្រព័ន្ធថាមពល និងធានាការគណនាបានត្រឹមត្រូវ។

ជាសង្ខេប មាត្រាសាស្ត្រមានផលប្រយោជន៍សម្រាប់សង្គម ដូចខាងក្រោម៖

- មាត្រាសាស្ត្រផ្តល់ការការពារដល់ប្រជាពលរដ្ឋ តាមរយៈការថ្លឹង និងវាស់វាល់ ដែលអាចទុកចិត្តបាន នៃទម្ងន់ និងរង្វាស់រង្វាល់ក្នុងផ្នែកវេជ្ជសាស្ត្រ
- សម្របសម្រួលឱ្យមានការធ្វើពាណិជ្ជកម្មដោយយុត្តិធម៌ តាមរយៈការធ្វើសុខដុមនីយកម្ម នៃស្តង់ដារជាលាយលក្ខអក្សរ ស្តង់ដារមាត្រាសាស្ត្រដែលមានភាពទៀងទាត់ និងការបញ្ជាក់ទទួលស្គាល់ជាអន្តរជាតិ
- មាត្រាសាស្ត្រជំរុញដល់នវានុវត្តន៍នៃឧស្សាហកម្ម តាមរយៈការលើកកម្ពស់សមត្ថភាពគ្រប់គ្រងផលិតផល និងដំណើរការតម្លើង ដោយប្រើបច្ចេកទេសផលិត/តម្លើងដែលមានភាពជាក់លាក់កម្រិតខ្ពស់ គាំទ្រដោយបច្ចេកទេសថ្លឹង និងវាស់វាល់ដែលមានភាពជាក់លាក់កម្រិតខ្ពស់
- មាត្រាសាស្ត្រគាំទ្រដល់បទប្បញ្ញត្តិ ដោយផ្តល់រង្វាស់រង្វាល់គោល (Measurement References) សម្រាប់ជាឱវាទគោលនយោបាយ ទិសដៅ ការវាយតម្លៃភាពអនុលោម និងការត្រួតពិនិត្យផ្ទៀងផ្ទាត់ និង
- មាត្រាសាស្ត្រជួយសម្រេចគោលដៅសង្គម តាមរយៈការសន្សំសំចៃ ឬ កាត់កាត់បន្ថយការប្រើប្រាស់ធនធាន។ល។

## ២.១.៤. ជំពូកនៃការងារមាត្រាសាស្ត្រ

មាត្រាសាស្ត្រត្រូវបានបែងចែក ជា បី ជំពូក ជាមួយនឹងកម្រិតនៃភាពស្មុគស្មាញ និងសុក្រឹតភាពផ្សេងៗគ្នា៖ វិទ្យាសាស្ត្រមាត្រាសាស្ត្រ មាត្រាសាស្ត្រឧស្សាហកម្ម និងនីត្យាកូលមាត្រាសាស្ត្រ។ មាត្រាសាស្ត្រទាំងបីជំពូក តម្រូវឱ្យមានការអភិវឌ្ឍព្រមគ្នា ដើម្បីផ្តល់ជាគុណប្រយោជន៍ ពេញលេញដល់តម្រូវការឧស្សាហកម្ម និងសង្គម។

១- វិទ្យាសាស្ត្រមាត្រាសាស្ត្រ (Scientific Metrology) - សំដៅលើការរៀបចំ និងបង្កើតស្តង់ដារមាត្រាសាស្ត្រ (Measurement Standards) ឬ វិធីសាស្ត្រគោល និងការថែរក្សារបស់វា (កម្រិតខ្ពស់)

២- មាត្រាសាស្ត្រឧស្សាហកម្ម (Industrial Metrology) - មានតួនាទីធានានូវដំណើរការគ្រប់គ្រាន់ នៃឧបករណ៍មាត្រាសាស្ត្រ ដែលត្រូវបានប្រើប្រាស់ក្នុងឧស្សាហកម្ម ក្នុងផលិតកម្មនិងដំណើរការធ្វើតេស្ត ដើម្បីធានាគុណភាពនៃជីវិតប្រជាពលរដ្ឋ និងសម្រាប់ការសិក្សាស្រាវជ្រាវ និង

៣- នីត្យានុកូលមាត្រាសាស្ត្រ (Legal Metrology) - ពាក់ព័ន្ធនឹងសុក្រឹតភាពនៃការថ្លឹង និងវាស់វាល់ ទៅតាមវិស័យ ឬ ផ្នែកនានា ដែលការថ្លឹង និងវាស់វាល់នោះមានផលប៉ះពាល់ទៅលើតម្លាភាព នៃប្រតិបត្តិការសេដ្ឋកិច្ច សុខភាព និងសុវត្ថិភាព។ ការថ្លឹង និងវាស់វាល់នេះ តម្រូវឱ្យមានការត្រួតពិនិត្យផ្ទៀងផ្ទាត់ជាបញ្ញត្តិ (Legal Verification) សម្រាប់ឧបករណ៍មាត្រាសាស្ត្រ។

សុក្រឹតភាពនៃការថ្លឹង និងវាស់វាល់កម្រិតខ្ពស់បំផុត នៅក្នុងផ្នែកណាមួយ ត្រូវបានបញ្ជាក់ក្នុងមាត្រាសាស្ត្រគ្រឹះ (Fundamental Metrology) ដែលមិនមាននិយមន័យជាអន្តរជាតិទេ។ មាត្រាសាស្ត្រគ្រឹះ អាចពណ៌នាថា ជាផ្នែកមួយនៃវិទ្យាសាស្ត្រមាត្រាសាស្ត្រ ដែលជាកម្រិតខ្ពស់បំផុត រួមផ្សំដោយផ្នែកខ្លះនៃនីត្យាកូលមាត្រាសាស្ត្រ និងមាត្រាសាស្ត្រឧស្សាហកម្ម ដែលទាមទារឱ្យមានសមត្ថភាពវិទ្យាសាស្ត្រ[15]។

## ២.១.៥. មាត្រាសាស្ត្រជាផ្នែកដ៏សំខាន់នៃហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ

ហេដ្ឋារចនាសម្ព័ន្ធគុណភាព (Quality Infrastructure) មានធាតុសំខាន់ៗចំនួន ០៥ (ប្រាំ) រួមមាន៖ ១-មាត្រាសាស្ត្រ (ការធានានៃការថ្លឹង និងវាស់វាល់ដែលមានភាពពិតប្រាកដ និងទុកចិត្ត) ២-ស្តង់ដារ (និយមន័យនៃទម្រង់លក្ខណៈវិមាត្រ កម្រិតលំអៀង/Tolerance ។ល។) ៣-ការវាយតម្លៃទទួលស្គាល់ (ការទទួលស្គាល់សមត្ថភាពបច្ចេកទេស) ៤-វិញ្ញាបនបត្រកម្ម/Certification (អនុលោមភាពជាមួយលក្ខខណ្ឌតម្រូវ ដែលកំណត់ដោយស្តង់ដារ) និង ៥-ការធ្វើតេស្ត (ការវិភាគ ទម្រង់លក្ខណៈ ធាតុផ្សំ លក្ខណៈសម្បត្តិ ។ល។)[16]។

តាមការប្រតិបត្តិជាអន្តរជាតិ ហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ ត្រូវមានស្ថាប័នគុណភាព យ៉ាងតិចចំនួនបី រួមមាន៖ ១-ស្ថាប័នស្តង់ដារជាតិ (National Standards Body) ដែលមានតួនាទីបង្កើតស្តង់ដារនានា ផ្តល់លទ្ធភាពនៃការប្រើប្រាស់ស្តង់ដារដែលមានស្រាប់ និងជួយសហគ្រិនក្នុងការប្រើប្រាស់ស្តង់ដារ ដើម្បីបំពេញលក្ខខណ្ឌនានាដែលទាមទារដោយអតិថិជនក្នុងស្រុក និងអន្តរជាតិ ២-វិទ្យាស្ថានមាត្រាសាស្ត្រជាតិ (National Metrology Institute) ថែរក្សាស្តង់ដារមាត្រាសាស្ត្រជាតិ ជាមួយនឹងការតាមដានផ្ទៀងផ្ទាត់អន្តរជាតិ និងការផ្ទេរការតាមដាននេះ ទៅស្តង់ដារមាត្រាសាស្ត្របន្ទាប់ រួមទាំងផ្តល់សេវាព្យាសកម្មដែលអាចទុកចិត្តបាន និង ៣-ស្ថាប័នជាតិវាយតម្លៃទទួលស្គាល់ (National Accreditation Body) ដែលមានគោលដៅធានាចំពោះសមត្ថភាពបច្ចេកទេស នៃមន្ទីរពិសោធន៍ អង្គភាពត្រួតពិនិត្យ និងការបញ្ជាក់វិញ្ញាបនបត្រគុណភាពក្នុងប្រទេស។

---

[15] Government of Montenegro. (2015). *Strategy of Metrology Development in Montenegro for Period 2016-2018*, page 1-3

[16] និយមន័យ ហេដ្ឋារចនាសម្ព័ន្ធគុណភាពរបស់ PTB




**រូបភាពទី១៖ មាត្រាសាស្ត្រជាផ្នែកដ៏សំខាន់នៃហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ**

## ២.២. ស្ថានភាពនៃវិស័យមាត្រាសាស្ត្រនៅកម្ពុជា

ការអភិវឌ្ឍវិស័យមាត្រាសាស្ត្រនៅកម្ពុជា នៅមានកម្រិតនៅឡើយ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់និងពិភពលោក។ ដោយសារមាត្រាសាស្ត្រមានអត្ថន័យទូលំទូលាយ គ្របដណ្តប់រាល់ការថ្លឹង និងវាស់វាល់ ការយល់ដឹងស៊ីជម្រៅរបស់មហាជន (ទាំងផ្នែកឯកជន និងសាធារណៈ) លើការងារមាត្រាសាស្ត្រនៅមានកម្រិត ថ្វីបើមាត្រាសាស្ត្រប៉ះពាល់ដោយផ្ទាល់នឹងជីវិតប្រចាំថ្ងៃក៏ដោយ។ ការងារមាត្រាសាស្ត្រត្រូវបានយកចិត្តទុកដាក់ នៅពេលប្រទេសកម្ពុជា បានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ១៩៩២ ដែលតម្រូវឱ្យកម្ពុជាអនុលោមតាមបទប្បញ្ញត្តិ និងស្តង់ដារមាត្រាសាស្ត្រ ដែលទទួលស្គាល់ជាអន្តរជាតិ ដើម្បីអាចជ្រៀតចូលក្នុងទីផ្សារអន្តរជាតិ។ ចាប់ពីពេលនោះមក ស្ថាប័នទទួលខុសត្រូវ ត្រូវបានអភិវឌ្ឍខ្លួនជាបន្តបន្ទាប់ (ពីការិយាល័យរង្វាស់រង្វាល់ទៅជានាយកដ្ឋានមាត្រាសាស្ត្រ និងចុងក្រោយក្លាយទៅជាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ) ដើម្បីឆ្លើយតបនឹងតួនាទី-ភារកិច្ច និងតម្រូវការសេវាកម្មមាត្រាសាស្ត្រក្នុងប្រទេសកម្ពុជា ដែលមានការកើនឡើងស្របតាមការរីកចម្រើនផ្នែកសេដ្ឋកិច្ចជាតិ។ ទោះយ៉ាងណា រហូតមកដល់ពេលនេះ ប្រភេទនិងវិសាលភាពនៃសេវាកម្មមាត្រាសាស្ត្រនៅមានកម្រិតនៅឡើយ បើប្រៀបធៀបទៅនឹងតម្រូវការ (សូមមើលបន្ថែមអំពីការប្រឈម ក្នុងផ្នែកខាងក្រោម)។

មានការតាំងចិត្តនយោបាយខ្ពស់ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិនៅកម្ពុជា ទៅតាមនិយាមប្រតិបត្តិអន្តរជាតិ ជាមួយនឹងគោលដៅ ក្នុងការពង្រឹងវិស័យផលិតកម្ម ឱ្យមានភាពប្រកួតប្រជែងកាន់តែខ្លាំង បង្កើតតម្លៃបន្ថែម និងបង្កើតផលិតភាព ក៏ដូចជាឆ្លើយតបនឹងលក្ខខណ្ឌតម្រូវរបស់អ្នកទិញ ពាក់ព័ន្ធនឹងសុវត្ថិភាព និងគុណភាព។ ក្រសួងបានបង្កើតស្ថាប័នសំខាន់ៗសម្រាប់គាំទ្រដល់ផ្នែកគុណភាព រួមមាន៖ ១-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) ២-វិទ្យាស្ថានស្តង់ដារកម្ពុជា (ជាស្ថាប័នស្តង់ដារជាតិទទួលខុសត្រូវក្នុងការរៀបចំ និងបោះផ្សាយអំពីស្តង់ដារកម្ពុជា និងគោលការណ៍ណែនាំសម្រាប់ផលិតផល ទំនិញ សម្ភារ សេវាកម្ម និងប្រតិបត្តិការ ។ល។) ៣-នាយកដ្ឋានវាយតម្លៃទទួលស្គាល់ (ជាអាជ្ញាធរមានសមត្ថកិច្ច ចំពោះការវាយតម្លៃទទួលស្គាល់លើស្ថាប័ន ដែលវាយតម្លៃភាពអនុលោមនៅកម្ពុជា តាមរយៈបង្កើតប្រព័ន្ធវាយតម្លៃទទួលស្គាល់មួយ មានលក្ខណៈមិនលំអៀង ឯករាជ្យ និងតម្លាភាព ស្របតាមច្បាប់ និងបទប្បញ្ញត្តិកម្ពុជា និងលក្ខណៈវិនិច្ឆ័យស្តង់ដារអន្តរជាតិ ។ល។) ៤-មន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (មានគោលដៅលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផល ដើម្បីប្រកួតប្រជែងលើទីផ្សារអន្តរជាតិ តាមរយៈការធ្វើតេស្ត និងវិភាគ ផលិតផល ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាម្ហូបអាហារ ដែលមានការទទួលស្គាល់ពីថ្នាក់ជាតិ និងអន្តរជាតិ ។ល។)។ ស្ថាប័នទាំងបួនសុទ្ធតែមានការប្តេជ្ញាចិត្ត ក្នុងការលើកកម្ពស់ប្រតិបត្តិការរបស់ខ្លួនទៅតាមនិយាមដែលទទួលស្គាល់ជាអន្តរជាតិ។

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) គឺជាអង្គភាពមាត្រាសាស្ត្រជាតិ ដែលត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងរាល់សកម្មភាព និងសេវាកម្មពាក់ព័ន្ធនឹងការងារមាត្រាសាស្ត្រ។ ម.ម.ជ មាននាយកដ្ឋានបច្ចេកទេស ចំនួនបី (នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម និងនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ) ដែលឈ្មោះនាយកដ្ឋានទាំងបីនេះ ស្របតាមអត្ថន័យ និងការប្រតិបត្តិអន្តរជាតិក្នុងការៈ

- ថែរក្សា និងផ្សព្វផ្សាយនូវស្តង់ដាររមាត្រាសាស្ត្រគោលជាតិ
- ផ្តល់សេវាកម្មមាត្រាសាស្ត្រគ្រប់ប្រភេទ ដល់អ្នកប្រើប្រាស់ចុងក្រោយ សម្រាប់ធានាគុណភាព និង
- អនុវត្តការវាយតម្លៃអនុលោមភាពមាត្រាសាស្ត្រ ទៅតាមបទប្បញ្ញត្តិបច្ចេកទេសមាត្រាសាស្ត្រ។

ក្នុងគោលបំណង ធ្វើសុខដុមនីយកម្ម និងសមាហរណកម្មនៃការប្រតិបត្តិមាត្រាសាស្ត្រ ទៅតំបន់និងពិភពលោក មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ បានចងបណ្តាញ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាញមាត្រាសាស្ត្រអន្តរជាតិជាច្រើន រួមមាន៖ ការិយាល័យអន្តរជាតិទម្ងន់ និងរង្វាស់រង្វាល់ (BIPM) អង្គការនីត្យានុកូលមាត្រាសាស្ត្រអន្តរជាតិ (OIML) អង្គការកម្មវិធីមាត្រាសាស្ត្រអាស៊ីប៉ាស៊ីហ្វិក (APMP) អង្គការវេទិកានីត្យានុកូលមាត្រាសាស្ត្រ (APLMF) ក្រុមអ្នកជំនាញមាត្រាសាស្ត្រអាស៊ាន (ASEAN EGM) និងគណៈកម្មាធិការពិគ្រោះយោបល់អាស៊ានស្តីពីស្តង់ដារ និងគុណភាពលើផ្នែកនីត្យានុកូលមាត្រាសាស្ត្រ (ACCSQ-WG3) ។

បច្ចុប្បន្ន មានស្ថាប័នដៃគូអភិវឌ្ឍ និងស្ថាប័នពាក់ព័ន្ធមួយចំនួន កំពុងផ្តល់ការគាំទ្រសមត្ថភាពបច្ចេកទេស និងសម្ភារ ដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិនៅកម្ពុជា (រួមទាំងវិស័យមាត្រាសាស្ត្រ)។ ស្ថាប័នទាំងនោះ មានដូចជាវិទ្យាស្ថានមាត្រាសាស្ត្រជាតិអាល្លឺម៉ង់ (PTB) វិទ្យាស្ថានមាត្រាសាស្ត្រជាតិចិន (NIM, China) វិទ្យាស្ថានមាត្រាសាស្ត្រជាតិថៃ (NIMT) អង្គការសហប្រជាជាតិអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) និងកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC)។ល។

## ២.៣. វឌ្ឍនភាព និងសមិទ្ធផលសំខាន់ៗកន្លងមក

រហូតមកដល់ពេលនេះ តួនាទីនិងសារសំខាន់នៃមាត្រាសាស្ត្រនៅកម្ពុជា ត្រូវបានទទួលស្គាល់កាន់តែ ខ្លាំងឡើង ដោយមានការអភិវឌ្ឍជាបន្តបន្ទាប់ ដែលជំរុញដោយគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគាំទ្រ ដោយស្ថាប័នពាក់ព័ន្ធជាច្រើន។ វឌ្ឍនភាពសំខាន់ៗដែលគួរឱ្យកត់សម្គាល់ រួមមាន៖

១- តួនាទីរបស់អង្គភាពជាតិទទួលខុសត្រូវលើការងារមាត្រាសាស្ត្រ កាន់តែមានសារសំខាន់ ដែលគាំទ្រការថ្លឹង និងវាស់វាល់ប្រកបដោយសុក្រឹតភាព ដល់វិស័យពាក់ព័ន្ធជាច្រើន ជាពិសេសវិស័យឧស្សាហកម្ម/ផលិតកម្ម (ផ្តោតលើសហគ្រាសធុនតូច និងមធ្យម)។ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) កំពុងក្លាយខ្លួន ជាអង្គភាពជាតិដ៏មានឧត្តមភាព ដើរតួជាតួអង្គលេចធ្លោរក្នុងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិរបស់កម្ពុជា ដែលកំពុងដើរតាមគំរូនៃការប្រតិបត្តិមាត្រាសាស្ត្ររបស់ប្រទេសដទៃលើពិភពលោក។ ម.ម.ជ កំពុងត្រូវបានស្គាល់ជាបណ្តើរៗ ជាអង្គភាពមាត្រាសាស្ត្រជាតិស្របច្បាប់នៅកម្ពុជា។

២- ប្រតិបត្តិករមាត្រាសាស្ត្រ (ពិសេស ម.ម.ជ) និងអ្នកប្រើប្រាស់សេវាកម្មមាត្រាសាស្ត្រ អាចពន្យល់បានល្អ អំពីផលប្រយោជន៍នៃមាត្រាសាស្ត្រ និងទំនាក់ទំនងរបស់វា ទៅវិស័យដទៃទៀត (វិស័យផលិតកម្ម សុខាភិបាល បរិស្ថាន សំណង់ អគ្គិសនី ។ល។)។ ការថ្លឹង និងវាស់វាល់ត្រឹមត្រូវ បានក្លាយជាបញ្ហាដែលត្រូវបានយកចិត្តទុកដាក់ខ្លាំងនៅកម្ពុជា ដោយវាបានប៉ះពាល់ដោយផ្ទាល់ដល់ជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ការថ្លឹង និងវាស់វាល់ត្រឹមត្រូវ ជួយលើកកម្ពស់គុណភាពផលិតផល ធានាយុត្តិធម៌នៃការធ្វើពាណិជ្ជកម្ម លើកកម្ពស់ ជំនឿទុកចិត្តរបស់អ្នកផ្គត់ផ្គង់ អ្នកទិញឬអ្នកប្រើប្រាស់ទំនិញ និងឈានទៅបង្កើនការប្រកួតប្រជែងលើទីផ្សារអន្តរជាតិ តាមរយៈការឆ្លើយតបនឹងលក្ខខណ្ឌឬការអនុលោម សម្រាប់ស្តង់ដារ និងគុណភាព។

៣- បច្ចុប្បន្ន សេវាកម្មមាត្រាសាស្ត្រនៅកម្ពុជា កំពុងផ្តល់ និងប្រើប្រាស់ដោយឧស្សាហកម្ម សិប្បកម្ម សហគ្រាស និងអាជីវកម្ម។ សេវាកម្មមាត្រាសាស្ត្រសំខាន់ៗកំពុងផ្តល់ រួមមាន៖ សេវាព្យាសកម្ម (ទៅលើទម្ងន់ ចំណុះ ម៉ាស់ ប្រវែង សម្ពាធ សីតុណ្ហភាព...) និងសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់ ដើម្បីពង្រឹងការអនុវត្តច្បាប់ និង បទប្បញ្ញត្តិមាត្រាសាស្ត្រ។ អ្នកប្រើប្រាស់សេវាកម្មមាត្រាសាស្ត្រ មានជាអាទិ៍អ្នកប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រផ្ទាល់ សម្រាប់គោលដៅផលិតកម្ម ពាណិជ្ជកម្ម និងសេវាកម្ម (ក្រុមហ៊ុន ឯកជន និងសាធារណៈ) និងមន្ទីរពិសោធន៍។ ក្រុមហ៊ុនជាច្រើនបានប្រើសេវាកម្មព្យាសកម្ម ដើម្បីបំពេញលក្ខខណ្ឌ ក្នុងការដាក់ពាក្យដើម្បីវាយតម្លៃទទួលស្គាល់ ជាអន្តរជាតិ (ISO) ដែលតម្រូវដោយអ្នកទិញ។ អ្នកប្រើប្រាស់សេវាកម្មមាត្រាសាស្ត្រ បានផ្តល់យោបល់ថា សេវាកម្ម មាត្រាសាស្ត្រដែលផ្តល់ក្នុងស្រុក មានភាពងាយស្រួលក្នុងការទំនាក់ទំនង មានតំលៃសមរម្យ និងមានគុណភាព ដែលអាចទទួលយកបាន។ អ្នកពាក់ព័ន្ធដែលបានពិគ្រោះយោបល់ បានការព្យាករណ៍ថា តម្រូវការសេវាព្យាសកម្មនឹង មានការកើនឡើងថែមទៀតនាពេលអនាគត ដោយហេតុថា រោងចក្រ/សហគ្រាស កាន់តែទទួលស្គាល់សារប្រយោជន៍ នៃការធ្វើព្យាសកម្ម ហើយនឹងព្យាយាមស្វែងរកសេវាកាន់តែច្រើនឡើង ចំនួនមន្ទីរពិសោធន៍នៅកម្ពុជាកំពុងមានការ កើនឡើង ដែលនឹងមានតម្រូវការសេវាព្យាសកម្មក្នុងស្រុកកាន់តែច្រើនផងដែរ។

នៅចុងឆ្នាំ២០២១ មានការរាយការណ៍មកថា ដៃបាញ់ប្រេង នៅតាមស្ថានីយ៍ប្រេងឥន្ធនៈ ស្ទើរតែ ១០០% នៅទូទាំងប្រទេសត្រូវបានត្រួតពិនិត្យផ្ទៀងផ្ទាត់។ ឧបករណ៍មាត្រាសាស្ត្រចំនួន ៧០០ គ្រឿង(ដែលជា របស់ក្រុមហ៊ុនចំនួន ១៦៤) ត្រូវបានធ្វើព្យាសកម្ម ឧបករណ៍មាត្រាសាស្ត្រចំនួន ៩៧ គ្រឿង របស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី-ខេត្តត្រូវបានធ្វើព្យាសកម្ម ជញ្ជីងគោនចំនួន ១៣៣ និងស៊ីទែនប្រេង ឥន្ធនៈចំនួន ៩៧ និងដៃបាញ់ប្រេងឥន្ធនៈចំនួន ២៦ ៩២០ ត្រូវបានត្រួតពិនិត្យផ្ទៀងផ្ទាត់[17]។

៤- មានការតភ្ជាប់បណ្តាញ និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាញ និងស្ថាប័នមាត្រាសាស្ត្រនានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ រៀនសូត្រ និងធ្វើសុខដុមនីយកម្មការងារមាត្រាសាស្ត្រ។ ម.ម.ជ មានទំនាក់ទំនង និង ជាសមាជិកជាមួយបណ្តាញអង្គការមាត្រាសាស្ត្រនៅគ្រប់កម្រិត៖ អាស៊ាន អាស៊ីប៉ាស៊ីហ្វិក និងពិភពលោក (ដូចជា ASEAN EGM, ACCSQ-WG3, APMP, APLMF, BIPM, OIML)។ ទំនាក់ទំនងនេះ បានផ្តល់ឱកាសឱ្យ ម.ម.ជ អភិវឌ្ឍសេវាកម្ម និងការប្រតិបត្តិមាត្រាសាស្ត្ររបស់ខ្លួន ទៅតាមនិយាមដែលទទួលស្គាល់ជាអន្តរជាតិ ជាបណ្តើរៗ ។

៥- ក្របខណ្ឌគាំទ្រនានា ត្រូវបានបង្កើតឡើង សម្រាប់អភិវឌ្ឍវិស័យមាត្រាសាស្ត្រឱ្យក្លាយជាកម្លាំងគាំទ្រ គុណភាពដ៏រឹងមាំ សម្រាប់អភិវឌ្ឍវិស័យដទៃទៀត ដែលជំរុញដល់ការលូតលាស់សេដ្ឋកិច្ចជាតិ។ ក្របខណ្ឌគាំទ្រ ទាំងនេះរួមមាន៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម គោលនយោបាយគុណភាពជាតិ ច្បាប់ស្តីពីមាត្រាសាស្ត្រ និង អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលក្នុង នោះមានកំណត់តួនាទី និងរចនាសម្ព័ន្ធ របស់ ម.ម.ជ ជាអង្គភាពមាត្រាសាស្ត្រជាតិ។

## ២.៤. បញ្ហាប្រឈមដែលត្រូវដោះស្រាយ

ទន្ទឹមនឹងវឌ្ឍនភាពខាងលើ វិស័យមាត្រាសាស្ត្រនៅកម្ពុជា នៅជួបការប្រឈម និងឧបសគ្គជាច្រើនទៀត ដែលត្រូវពិចារណាដោះស្រាយ។ ការប្រឈមសំខាន់ៗរួមមាន៖

**១- ការយល់ដឹងរបស់សាធារណជនអំពីមាត្រាសាស្ត្រនៅមានកម្រិត**

ពាក្យមាត្រាសាស្ត្រ និងតួនាទីរបស់វា មិនត្រូវបានមហាជនយល់ដឹងឱ្យបានទូលំទូលាយនៅឡើយទេ ទាំងវិស័យឯកជន និងសាធារណៈ (ទាំងអ្នកប្រើសេវាកម្មមាត្រាសាស្ត្រ និងអ្នកប្រើប្រាស់ទំនិញ ជាពិសេស សហគ្រាស

[17] របាយការណ៍បូកសរុបការងាររបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២១, ទំព័រ ៥០-៥២

ខ្នាតតូច និងមធ្យម) លើកលែងតែអ្នកអនុវត្ត/អ្នកបច្ចេកទេសមាត្រាសាស្ត្រ ទើបអាចយល់បាន។ មានការលើកឡើងជារឿយៗថា ក្នុងភាសាសាមញ្ញ ពាក្យ "ការថ្លឹង និងវាស់វាល់ ឬ ទម្ងន់ និងរង្វាស់រង្វាល់ត្រឹមត្រូវ" មានលក្ខណៈងាយយល់ជាងពាក្យ "មាត្រាសាស្ត្រ" ហើយប្រជាពលរដ្ឋមានភាពងាយស្រួល ក្នុងការផ្សារភ្ជាប់សារសំខាន់របស់វាទៅនឹងជីវិតប្រចាំថ្ងៃ។ ខណៈដែលមនុស្សជាច្រើនយល់ពីសារសំខាន់នៃទម្ងន់ និងរង្វាស់រង្វាល់ត្រឹមត្រូវ (គីឡូក្រាម លីត្រ ប្រវែង) ដូចជានៅមានការលំបាកក្នុងការស្វែងរកស្ថាប័នទទួលខុសត្រូវ សម្រាប់ជួយ នៅពេលជួបប្រទះបញ្ហាទម្ងន់ និងរង្វាស់រង្វាល់មិនត្រឹមត្រូវ ក្នុងពេលទិញទំនិញប្រើប្រាស់[18]។ ការយល់ដឹងមានកម្រិតលើការងារមាត្រាសាស្ត្របណ្តាលមកពីការផ្សព្វផ្សាយពីមាត្រាសាស្ត្រមិនទាន់គ្រប់គ្រាន់ ទៅអតិថិជននានា និងមហាជន កង្វះខាតការធ្វើឱ្យមានការយល់ដឹង និងការអប់រំ (ក្នុងប្រព័ន្ធអប់រំ) អំពីប្រធានបទមាត្រាសាស្ត្រ ក៏ដូចជាការបណ្តុះវប្បធម៌នៃការឱ្យតម្លៃលើគុណភាព (មាត្រាសាស្ត្រ)។ ជារឿយៗមានការលើកឡើងថា ការផ្សព្វផ្សាយ បច្ចុប្បន្នហាក់ដូចជាផ្តោតទៅលើនីត្យានុកូលមាត្រាសាស្ត្រច្រើន ដែលអាចធ្វើឱ្យយល់ថា ការប្រើសេវាមាត្រាសាស្ត្រ ដើម្បីអនុលោមតាមច្បាប់ ជាជាងប្រើប្រាស់ដោយស្មារតីភ្ញាក់រលឹក ដើម្បីពង្រឹងគុណភាពផលិតផល សំដៅលើកកម្ពស់ការប្រកួតប្រជែងលើទីផ្សារ។

## ២- ចំនួន/ប្រភេទសេវា គុណភាពសេវាកម្មមាត្រាសាស្ត្រ និងវិសាលភាពគ្របដណ្តប់នៅមានកម្រិត

ជាបឋម មានប្រភេទសេវាកម្មមាត្រាសាស្ត្រមួយចំនួន (សម្ពាធ ខ្យល់ ហ្គាស) ដែលមិនទាន់អាចផ្តល់សេវាក្នុងស្រុកបាននៅឡើយ (តម្រូវឱ្យអតិថិជនស្វែងរកសេវាកម្មមាត្រាសាស្ត្រនៅក្រៅប្រទេស) ហើយសេវាដែលមានស្រាប់ក៏មានដែនចន្លោះរង្វាស់រង្វាល់ (Measuring Range) នៅមានកម្រិតនៅឡើយ។ ចំនួនសេវាដែលបានផ្តល់ត្រូវបានមើលឃើញថា នៅមានចំនួនតិចនៅឡើយ បើប្រៀបធៀបនឹងចំនួនអ្នកដែលត្រូវការប្រើសេវា ហើយការផ្តល់សេវាមិនទាន់បានដល់អតិថិជនច្រើនវិស័យ/ផ្នែកនៅឡើយ។ ការប៉ាន់ប្រមាណតម្រូវការសេវាកម្មមាត្រាសាស្ត្រពីសហគមន៍ឧស្សាហកម្ម មិនទាន់ឆ្លើយតបបានគ្រប់ជ្រុងជ្រោយ ចំពោះតម្រូវការរបស់អ្នកប្រើប្រាស់/សហគ្រាសនៅឡើយ។ ការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ មិនទាន់មានប្រសិទ្ធភាពពេញលេញនៅឡើយ ។ ទាក់ទងនឹងគុណភាពសេវាកម្មមាត្រាសាស្ត្ររបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ការផ្តល់សេវាបច្ចុប្បន្នប្រើពេលវែង ធ្វើឱ្យអតិថិជនមិនអាចយកលទ្ធផលទៅប្រើប្រាស់បានទាន់ពេលវេលា (ប្រការនេះទាក់ទងនឹងនីតិវិធីប្រតិបត្តិការងារ និងធនធានមនុស្ស)។ អតិថិជនដែលបានចូលរួមពិគ្រោះយោបល់[19] បានលើកឡើងពីការរំពឹងទុក ដែលចង់បាន ១-ម.ម.ជ គួរជាតួអង្គដែលគាំទ្រសំខាន់ដល់ការអភិវឌ្ឍវិស័យឯកជន ២-មានសេវាកម្មមាត្រាសាស្ត្រគ្រប់ប្រភេទអាចទទួលបាននៅក្នុងស្រុក ៣-សេវាព្យាសកម្មអាចទុកចិត្តបាន ដោយមានការទទួលស្គាល់ជាអន្តរជាតិ ៤-សេវាព្យាសកម្មដែលមានត្រូវបានផ្សព្វផ្សាយដល់សហគ្រាស និងអ្នកប្រើប្រាស់ និង ៥-ដំណើរការផ្តល់សេវាមាត្រាសាស្ត្រគួរមានការកែលម្អ (រហ័ស និងងាយស្រួល)។ បច្ចុប្បន្ន ម.ម.ជ មានការលំបាកក្នុងការថែរក្សា ការវាយតម្លៃទទួលស្គាល់ជាអន្តរជាតិ (ISO/IEC 17025) និងបង្កើននូវការវាយតម្លៃទទួលស្គាល់លើសេវាព្យាសកម្មផ្សេងៗ ដែលប្រការនេះបានលើកជាសំណួរអំពីកម្រិតនៃការជឿទុកចិត្តមកលើសេវាកម្មមាត្រាសាស្ត្រក្នុងស្រុក។

## ៣- កិច្ចសហការជាមួយវិស័យឯកជន មិនទាន់រឹងមាំ

អង្គភាពមាត្រាសាស្ត្រជាតិ នៅមានការលំបាកក្នុងការផ្លាស់ប្តូរ និងទាញកិច្ចសហការពីវិស័យឯកជនឧស្សាហកម្ម សិប្បកម្ម សហគ្រាស និងអាជីវកម្ម ផ្សេងៗ ដូច្នេះ ធ្វើឱ្យមានការលំបាកក្នុងការរៀបចំអភិវឌ្ឍន៍សេវាឱ្យឆ្លើយតបនឹងតម្រូវការ និងអាទិភាពរបស់ វិស័យផលិតកម្មនៅកម្ពុជា។ ការចូលរួមរបស់វិស័យឯកជន ជាទូទៅមានកម្រិត ដូច្នេះ បង្ករជាការលំបាក ក្នុងការលើកកម្ពស់ការប្រើប្រាស់សេវាមាត្រាសាស្ត្រតាមគោលការណ៍ស្ម័គ្រចិត្ត

---

[18] ទោះមិនមានការស្រាវជ្រាវជាក់លាក់ណាមួយក៏ដោយ នៅប្រទេសកម្ពុជា ការកេងបន្លំរង្វាស់រង្វាល់ (ថ្លឹងទម្ងន់មិនគ្រប់គីឡូ/ខាំ - ស៊ីភ្លែកជញ្ជីង វាល់ចំណុះមិនគ្រប់លីត្រ ប្រវែងមិនត្រូវ...) ពីសំណាក់អ្នកលក់ ត្រូវបានមើលឃើញថា កើតឡើងជាទូទៅគ្រប់ទីកន្លែង ដែលប្រការនេះ ធ្វើឱ្យអ្នកប្រើប្រាស់ទំនិញ បាត់បង់ផលប្រយោជន៍។

[19] សូមមើលឧបសម្ព័ន្ធ ៣.២ សម្រាប់ប្រភេទអតិថិជន ដែលបានចូលរួមផ្តល់យោបល់

(មិនមែនបែបបង្ខំ) ដែលចាត់ទុកថា មានប្រសិទ្ធភាព និងនិរន្តរភាពជាង ក្នុងការជួយលើកកម្ពស់គុណភាពផលិតកម្ម។ ស្ថាប័នជាតិ ម.ម.ជ មានការខ្វះខាតធនធានគ្រប់ប្រភេទ ដែលធ្វើឱ្យលទ្ធភាពផ្តល់សេវាមានកម្រិត ប្រការនេះតម្រូវឱ្យមានកិច្ចសហការជាមួយវិស័យឯកជន ដែលមានសមត្ថភាព និងធនធានគ្រប់គ្រាន់ ក្នុងការចូលរួមចំណែកផ្តល់សេវាមាត្រាសាស្ត្រប្រកបដោយគុណភាពដល់អតិថិជន ដើម្បីបំពេញចន្លោះប្រហោងនៃតម្រូវការ ដែលមិនអាចបំពេញផ្ទាល់ដោយ ម.ម.ជ។

### ៤- សមត្ថភាពរបស់អង្គភាពមាត្រាសាស្ត្រជាតិ (ម.ម.ជ) នៅមានកម្រិត

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ មានបទពិសោធន៍ការងារមាត្រាសាស្ត្រមិនទាន់គ្រប់គ្រាន់ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសក្នុងអាស៊ាន។ មន្ទីរពិសោធន៍ព្យាសកម្ម មិនទាន់បានអភិវឌ្ឍ និងវាយតម្លៃទទួលស្គាល់ជាអន្តរជាតិ (ISO/IEC 17025) នៅឡើយ ហើយ ម.ម.ជ នៅតែជួបការលំបាកក្នុងការថែរក្សាការវាយតម្លៃទទួលស្គាល់ជាអន្តរជាតិ ដែលមានស្រាប់ និងពង្រីកបន្ថែមការវាយតម្លៃទទួលស្គាល់ជាអន្តរជាតិ ទៅលើវិសាលភាពសេវាផ្សេងៗ។

ការប្រឈមសំខាន់មួយទៀតទាក់ទងនឹងសមត្ថភាពស្ថាប័ន គឺធនធានសម្ភារ និងថវិកា មានតិច មិនទាន់ឆ្លើយតបនឹងតម្រូវការ ក្នុងការផ្តល់សេវាមាត្រាសាស្ត្រប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។ ភាពចាំបាច់បំផុត គឺស្តង់ដារមាត្រាសាស្ត្រ ដែលមានតម្លៃថ្លៃ ហើយ ម.ម.ជ មិនទាន់មានលទ្ធភាពក្នុងការទិញ ស្តង់ដារមាត្រាសាស្ត្រទាំងនេះ ដើម្បីបំពាក់ឱ្យបានគ្រប់គ្រាន់ សម្រាប់ផ្តល់សេវាមាត្រាសាស្ត្រ។ កន្លងមក សកម្មភាពមួយ ចំនួនត្រូវបានអូសបន្លាយពេល ដោយសារកង្វះខាតថវិកាក្នុងការអនុវត្ត។

សម្រាប់ ៥ ឆ្នាំខាងមុខ ម.ម.ជ បានសម្រេចចាត់អាទិភាពបញ្ហាប្រឈមសំខាន់ៗចំនួន ៥ មកធ្វើការដោះស្រាយ រួមមាន៖

១- ការលើកកម្ពស់គុណភាព និងពង្រីកសេវាកម្មមាត្រាសាស្ត្រដែលជំរុញទីផ្សារ សំដៅលើកកម្ពស់គុណភាពផលិតភាព នវានុវត្តន៍ និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់ផ្នែកឯកជន ជាពិសេសសហគ្រាសធុនតូច និងមធ្យម។

២- ការបន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិមាត្រាសាស្ត្រ ដើម្បីការពារផលប្រយោជន៍អ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ទំនិញ និងលើកកម្ពស់សុវត្ថិភាព សុខភាព និងបរិស្ថាន។

៣- ការពង្រឹងគុណភាពសេវាកម្ម និងលើកកម្ពស់ជំនឿទុកចិត្តរបស់អ្នកប្រើប្រាស់សេវាកម្មមាត្រាសាស្ត្រតាមរយៈការធ្វើសុខដុមនីយកម្ម និងសមាហរណកម្ម លើការប្រតិបត្តិការងារមាត្រាសាស្ត្រឱ្យស្របតាមនិយាម ដែលទទួលស្គាល់ជាអន្តរជាតិ។

៤- លើកកម្ពស់ការយល់ដឹងរបស់មហាជនពីគ្រប់វិស័យ (សាធារណជន វិស័យផលិតកម្ម អ្នកប្រើប្រាស់ទំនិញ អ្នកធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយ) ទៅលើតួនាទីមាត្រាសាស្ត្រ តាមរយៈការផ្សព្វផ្សាយ ការអប់រំ និងការបណ្តុះវប្បធម៌គុណភាពទៅក្នុងសង្គម។

៥- បន្តអភិវឌ្ឍសមត្ថភាព (សមត្ថភាពមន្ត្រី និងសមត្ថភាព ម.ម.ជ ជាស្ថាប័ន[20]) និងពង្រឹងមុខងារគាំទ្រនានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍ និងផ្តល់សេវាកម្មមាត្រាសាស្ត្រ ប្រកបដោយប្រសិទ្ធភាព ឈានទៅសម្រេចគោលដៅ និងបេសកកម្ម។

---

[20] សមត្ថភាពមន្ត្រី សំដៅលើចំណេះ ជំនាញ បទពិសោធន៍ និងឥរិយាបថរបស់មន្ត្រីម្នាក់ៗ ដែលតម្រូវឱ្យមាន ដើម្បីអាចអនុវត្តតួនាទី-ភារកិច្ចរបស់ខ្លួនមានប្រសិទ្ធភាព។ សមត្ថភាពស្ថាប័ន សំដៅប្រព័ន្ធ ផែនការ ការដឹកនាំ គោលការណ៍ រចនាសម្ព័ន្ធ នីតិវិធីប្រតិបត្តិ ... ដែលជួយឱ្យស្ថាប័នដំណើរការបានដោយរលូន និងមានប្រសិទ្ធភាព។

## ជំពូកទី៣៖ ក្របខណ្ឌយុទ្ធសាស្ត្រវិស័យមាត្រាសាស្ត្រ ២០២៣-២០២៧

ការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់វិស័យមាត្រាសាស្ត្រកម្ពុជា ធ្វើឡើងតាមរយៈការពិចារណា នូវតក្កភាព និងកត្តាពាក់ព័ន្ធចាំបាច់នានា (ដូចបានពន្យល់ក្នុងរូបភាពទី២ ខាងក្រោម)។ ការអភិវឌ្ឍន៍សេដ្ឋកិច្ច ត្រូវតែបង្កើតការងារជាមួយនឹងកិច្ចការដែលមានតម្លៃបន្ថែម សម្រាប់ប្រជាពលរដ្ឋកម្ពុជា ដើម្បីអាចបង្កើនចំណូល និងលើកកម្ពស់កម្រិតជីវភាពឱ្យបានប្រសើរ។ ប្រការនេះអាចធ្វើទៅបាន តាមរយៈការលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់សហគ្រាសធុនតូច និងមធ្យម នៅក្នុងសេដ្ឋកិច្ចមួយដែលជំរុញដោយកម្លាំងទីផ្សារ។ បន្ថែមពីលើចំណុចនេះបញ្ញត្តិសម្រាប់កិច្ចការពារនៅលើទីផ្សារ (អ្នកប្រើប្រាស់ សុវត្ថិភាព សុខភាព បរិស្ថាន ) ត្រូវតែកំណត់ឱ្យបានច្បាស់ អនុវត្ត និងត្រួតពិនិត្យ ដើម្បីធានាឱ្យសេដ្ឋកិច្ចដែលជំរុញដោយទីផ្សារ ស្ថិតក្រោមលក្ខខណ្ឌតែមួយដូចៗគ្នាសម្រាប់អ្នកចូលរួមទាំងអស់គ្នា។




**រូបភាពទី២៖ តក្កភាពនៃការអភិវឌ្ឍយុទ្ធសាស្ត្រ សម្រាប់វិស័យមាត្រាសាស្ត្រនៅកម្ពុជា**

ចំណុចទាំង២ខាងលើ មាត្រាសាស្ត្រត្រូវការចាំបាច់នូវដៃគូយុទ្ធសាស្ត្រនានា ដើម្បីកិច្ចសហប្រតិបត្តិការ មានទាំងក្រុមគោលដៅ (អតិថិជន) និងអ្នកផ្តល់សេវាកម្មមាត្រាសាស្ត្រ (អ្នកពង្រីកសេវាគុណភាពបន្ត/Multipliers)។ ស្ថាប័នមាត្រាសាស្ត្រជាតិ ត្រូវមានយុទ្ធសាស្ត្រពង្រឹងកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន និងអ្នកពាក់ព័ន្ធ ដើម្បីអាចផ្តល់សេវាមាត្រាសាស្ត្រមានគុណភាព ប្រសិទ្ធភាព និងទាន់ពេលវេលា។ ក្នុងនាមជាអង្គភាពមាត្រាសាស្ត្រជាតិ និងជាអ្នកផ្តល់សេវាកម្មមាត្រាសាស្ត្រ ម.ម.ជ ត្រូវតែក្លាយជាមជ្ឈមណ្ឌលឧត្តមភាពនៃប្រទេសកម្ពុជា ដែលមានការទទួលស្គាល់សមត្ថភាពជាអន្តរជាតិ ដូច្នេះ ម.ម.ជ ត្រូវតែមានសមត្ថភាព មានការរៀបចំល្អ ធ្វើការប្រកបដោយប្រសិទ្ធផល និងធ្វើជាអ្នកផ្តល់សេវាដែលផ្តោតលើតម្រូវការអតិថិជន។ ប្រការនេះតម្រូវឱ្យ ម.ម.ជ ជាអង្គភាពមួយដែលដំណើរការល្អ ជាមួយនឹងប្រព័ន្ធគុណភាព និងសមត្ថភាពបច្ចេកទេស ដោយមានការវាយតម្លៃទទួលស្គាល់។

មាត្រាសាស្ត្រមិនអាចអភិវឌ្ឍតាមលក្ខណៈឯកោនិយមបានឡើយ តែត្រូវមានទំនាក់ទំនងជាមួយស្ថាប័នស្តង់ដារ និងស្ថាប័នវាយតម្លៃទទួលស្គាល់នានា។ ការប្រតិបត្តិមាត្រាសាស្ត្រ តម្រូវឱ្យមានការធ្វើសុខដុមនីយកម្ម និងសមាហរណកម្ម ជាមួយមាត្រាសាស្ត្រក្នុងតំបន់ និងពិភពលោក ដើម្បីអនុលោមទៅតាមនិយាម ដែលអនុវត្ត និងទទួលស្គាល់ជាអន្តរជាតិ។ វិស័យមាត្រាសាស្ត្រកម្ពុជាកំពុងចងបណ្តាញ និងបង្កើតកិច្ចសហប្រតិបត្តិការជាមួយនឹងបណ្តាញ/ស្ថាប័នមាត្រាសាស្ត្រអន្តរជាតិជាច្រើន។ បន្ថែមលើនេះ មានដៃគូអភិវឌ្ឍ និងស្ថាប័នអន្តរជាតិមួយចំនួនដែលគាំទ្រលើហេដ្ឋារចនាសម្ព័ន្ធគុណភាព កំពុងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍវិស័យមាត្រាសាស្ត្រនៅកម្ពុជា។

តម្រូវការនៃមាត្រាសាស្ត្រ គុណភាពសេវាកម្ម ពឹងផ្អែកទៅលើការយល់ដឹងពីតួនាទី និងផលប្រយោជន៍នៃមាត្រាសាស្ត្រ។ អ្នកប្រើប្រាស់ដែលមានការអប់រំល្អ និងមានតម្រូវការច្បាស់លាស់ គឺជាកម្លាំងជំរុញដល់គុណភាព។ ការអប់រំ ផ្សព្វផ្សាយ និងបណ្តុះវប្បធម៌គុណភាព គឺជាការធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

ដោយពិចារណាចំណុចពាក់ព័ន្ធខាងលើ សម្រាប់ ៥ ឆ្នាំខាងមុខ ម.ម.ជ បានសម្រេចជ្រើសរើសយុទ្ធសាស្ត្រចំនួន ៥ ក្នុងការជំរុញការអភិវឌ្ឍវិស័យមាត្រាសាស្ត្រឱ្យកាន់តែល្អប្រសើរ ក្នុងការបំពេញមុខងាររបស់ខ្លួន ដើម្បីជំរុញការលើកកម្ពស់គុណភាពនៃផលិតកម្ម ធានាដល់ការធ្វើពាណិជ្ជកម្មប្រកបដោយយុត្តិធម៌និងប្រកួតប្រជែង និងដើម្បីរួមចំណែកដល់ការលូតលាស់សេដ្ឋកិច្ចជាតិ។ យុទ្ធសាស្ត្រចំនួន ៤ ពាក់ព័ន្ធដោយផ្ទាល់ ក្នុងការពង្រឹង និងពង្រីកកម្មវិធីមាត្រាសាស្ត្រកម្ពុជា (ក្នុងនោះយុទ្ធសាស្ត្រទី១ និងទី២ ពាក់ព័ន្ធការផ្តល់សេវាកម្មមាត្រាសាស្ត្រ និងយុទ្ធសាស្ត្រទី៣និងទី៤ គាំទ្រដល់សកម្មភាពផ្តល់សេវាកម្ម/កម្មវិធី) ហើយយុទ្ធសាស្ត្រមួយទៀត(យុទ្ធសាស្ត្រទី៥) មានតួនាទីផ្តល់ការគាំទ្រចាំបាច់នានា ដល់សកម្មភាពកម្មវិធីមាត្រាសាស្ត្រ ដែលធ្វើឱ្យការផ្តល់សេវាមាត្រាសាស្ត្រនានាប្រព្រឹត្តទៅបានរលូន មានប្រសិទ្ធភាព និងទាន់ពេលវេលា។ ទិដ្ឋភាពរួមនៃយុទ្ធសាស្ត្រទាំងអស់ ត្រូវបានបង្ហាញដោយគំនូសបំព្រួញក្នុងរូបភាពទី៣ ខាងក្រោម។




**រូបភាពទី៣៖ គំនូសបំព្រួញនៃយុទ្ធសាស្ត្រមាត្រាសាស្ត្រ ៥ ឆ្នាំ និងទំនាក់ទំនង**

ដើម្បីសម្រេចយុទ្ធសាស្ត្រនីមួយៗ ចង្កោមសកម្មភាពជាអទិភាពចាំបាច់នានា ត្រូវបានកំណត់។ សម្រាប់ចង្កោមសកម្មភាពអាទិភាពនីមួយៗ សូចនាករជោក់លាក់ (លទ្ធផលដែលរំពឹងទុក) ត្រូវបានកំណត់ និងបង្កើតឡើង ដែលមាននាយកដ្ឋានទទួលខុសត្រូវច្បាស់លាស់ ក្នុងការអនុវត្ត (សូមមើលឧបសម្ព័ន្ធទី១)។ សូចនាករជាក់លាក់ នឹងត្រូវនាយកដ្ឋានទទួលខុសត្រូវយកទៅធ្វើសកម្មភាព ក្នុងក្របខណ្ឌនៃតួនាទីរបស់នាយកដ្ឋាន ដែលមានជំនាញច្បាស់លាស់ក្នុងការអនុវត្តប្រកបដោយវិជ្ជាជីវៈ។

## ៣.១. លើកកម្ពស់ និងពង្រីកសេវាកម្មមាត្រាសាស្ត្រដែលជួយគាំទ្រទីផ្សារ

យុទ្ធសាស្ត្រនេះមានគោលដៅធ្វើឱ្យសេវាកម្មមាត្រាសាស្ត្រនានា ត្រូវបានពង្រីកឱ្យកាន់តែទូលំទូលាយ ឆ្លើយតបនឹងតម្រូវការទីផ្សារ ដើម្បីជានាសុក្រឹតភាពនៃទម្ងន់ និងរង្វាស់សង្វាល់ និងបង្កើនគុណភាព និងផលិតភាព នៃផលិតផល សំដៅលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់ផ្នែកឧស្សាហកម្ម ជាពិសេសសហគ្រាសធុនតូចនិងមធ្យម។

<u>**ចង្កោមសកម្មភាពអាទិភាព**</u>

១.១. សិក្សាតម្រូវការ និងកំណត់អាទិភាព

១.២. បន្តអភិវឌ្ឍ និងពង្រឹងសមត្ថភាពមន្ទីរពិសោធន៍មាត្រាសាស្ត្រ

១.៣. ពង្រីកវិសាលភាពសេវាកម្មមាត្រាសាស្ត្រ

១.៤. កសាងភាពជាដៃគូសម្រាប់ផ្តល់សេវាកម្មមាត្រាសាស្ត្រ

១.៥. បង្កើត និងកែសម្រួលនិតិវិធីប្រតិបត្តិការងារ SOP (Standard Operation Procedures)

១.៦. ធ្វើទំនើបកម្ម/ឌីជីថលភាវូបនីយកម្មនៃដំណើរការផ្តល់សេវា (ឱ្យលឿន/រហ័ស)

១.៧. លើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន

១.៨. បង្កើត និងដាក់ឱ្យដំណើរការយន្តការផ្តល់យោបល់ត្រឡប់។

## ៣.២. ពង្រឹងការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ

យុទ្ធសាស្ត្រនេះ មានគោលដៅធ្វើឱ្យការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រត្រូវបានពង្រឹង ដើម្បីការពារផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ (ផលិតផលទំនិញ) ធានាការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្របានត្រឹមត្រូវ សំដៅលើកកម្ពស់សុវត្ថិភាព សុខភាព និងបរិស្ថាន និងធានាឱ្យការធ្វើពាណិជ្ជកម្មមានភាពយុត្តិធម៌ និងត្រឹមត្រូវ។

<u>**ចង្កោមសកម្មភាពជាអាទិភាព**</u>

២.១. បន្តអភិវឌ្ឍ ពង្រឹងនិងពង្រីកមធ្យោបាយ/ស្តង់ដារ ត្រួតពិនិត្យផ្ទៀងផ្ទាត់

២.២. ពង្រឹង និងពង្រីកវិសាលភាពសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់

២.៣. កសាងភាពជាដៃគូសម្រាប់ផ្តល់សេវាត្រួតពិនិត្យផ្ទៀងផ្ទាត់

២.៤. បង្កើត និងធ្វើបច្ចុប្បន្នភាព និតិវិធីប្រតិបត្តិ (SOP) សម្រាប់ពង្រឹងការអនុវត្តច្បាប់

២.៥. ពង្រឹងយន្តការក្នុងការការពារអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់

២.៦. បង្កើត និងអនុវត្តប្រព័ន្ធអនុម័តគំរូ

២.៧. បង្កើនការផ្តល់សេវា នាំចូល ផលិត តម្លើង ជួសជុល ឧបករណ៍មាត្រាសាស្ត្រ ទំនិញវេចខ្ចប់ ចុះបញ្ជីមាត្រាសាស្ត្រ ប្រើពាណិជ្ជសញ្ញាមាត្រាស្ត្រកម្ពុជា និងបញ្ជាក់ពីជំនាញមាត្រាសាស្ត្រ

២.៨. បង្កើតបទប្បញ្ញត្តិ ឧបករណ៍មាត្រាសាស្ត្រ ដែលបានបញ្ញត្តិសម្រាប់ក្រសួងអនុម័ត

២.៩. ពង្រឹង និងជំរុញការអនុវត្តការងារ របស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី-ខេត្ត (ការងារប្រតិភូកម្ម)។

## ៣.៣. សុខដុមនីយកម្ម និងសមាហរណកម្មការងារមាត្រាសាស្ត្រ

យុទ្ធសាស្ត្រនេះ មានគោលដៅធ្វើឱ្យការប្រតិបត្តិការងារមាត្រាសាស្ត្រនៅកម្ពុជា ធ្វើឡើងស្របទៅតាមគោលការណ៍ និងនិយាម ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។

**ចង្កោមសកម្មភាពជាអាទិភាព**

៣.១. បង្កើតក្រុមមន្ត្រីបច្ចេកទេស/ជំនាញតាមផ្នែកនីមួយៗ

៣.២. ចូលជាសមាជិកជាមួយអង្គការមាត្រាសាស្ត្រអន្តរជាតិក្នុងតំបន់ និងពិភពលោក ដើម្បីទាញប្រយោជន៍មកដល់វិស័យមាត្រាសាស្ត្រកម្ពុជា

៣.៣. ពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធ។

## ៣.៤. លើកកម្ពស់ការយល់ដឹងរបស់អ្នកពាក់ព័ន្ធអំពីមាត្រាសាស្ត្រ

យុទ្ធសាស្ត្រនេះ មានគោលដៅធ្វើឱ្យមាត្រាសាស្ត្រ និងសារសំខាន់របស់វា ត្រូវបានយល់ដឹង និងទទួលស្គាល់យ៉ាងទូលំទូលាយដល់សាធារណជន ផលិតករ ពាណិជ្ជករ សេវាករ និងអ្នកធ្វើការសម្រេចចិត្តគោលនយោបាយ។

**ចង្កោមសកម្មភាពជាអាទិភាព**

៤.១. បញ្ជ្រាបប្រធានបទ និងសារប្រយោជន៍មាត្រាសាស្ត្រក្នុងកម្មវិធីអប់រំ

៤.២. ផ្សព្វផ្សាយពីតួនាទី និងសារសំខាន់មាត្រាសាស្ត្រ តាមរយៈប្រព័ន្ធឌីជីថល

៤.៣. ផ្សព្វផ្សាយតាមរយៈសកម្មភាព ឬ ព្រឹត្តិការណ៍ផ្សេងៗ។

## ៣.៥. បន្តអភិវឌ្ឍសមត្ថភាព និងពង្រឹងមុខងារគាំទ្រទូទៅ

យុទ្ធសាស្ត្រនេះ មានគោលដៅធ្វើឱ្យសមត្ថភាព (មន្ត្រី និងស្ថាប័ន ម.ម.ជ) ត្រូវបានអភិវឌ្ឍបន្ថែមទៅតាមតម្រូវការ និងបរិបទ ហើយមុខងារគាំទ្រទូទៅនានា នឹងត្រូវបានពង្រឹង ដើម្បីជួយគាំទ្រយ៉ាងមានប្រសិទ្ធភាពនិងទាន់ពេលវេលា ដល់ការអនុវត្តកម្មវិធី/ផ្តល់សេវាកម្មមាត្រាសាស្ត្រ ឈានទៅសម្រេចបេសកកម្ម និងចក្ខុវិស័យ។

**ចង្កោមសកម្មភាពជាអាទិភាព**

៥.១. បន្តពង្រឹងសមត្ថភាពមន្ត្រី និងអភិវឌ្ឍសមត្ថភាពស្ថាប័ន ម.ម.ជ

៥.២. លើកកម្ពស់ការគ្រប់គ្រង និងលើកទឹកចិត្តមន្ត្រី

៥.៣. ពង្រឹងការគាំទ្ររដ្ឋបាល និងហិរញ្ញវត្ថុដល់ស្ថាប័នទាំងមូល

៥.៤. ពង្រឹង និងពង្រីកប្រព័ន្ធព័ត៌មានវិទ្យា និងសមត្ថភាពឌីជីថល សំដៅកែលម្អដំណើរការផ្តល់សេវាកម្មឱ្យរហ័ស និងងាយស្រួល

៥.៥. បង្កើនការកៀរគរធនធាន (សម្ភារឬឧបករណ៍ ជំនាញបច្ចេកទេស និងថវិកា)។

## ជំពូកទី៤៖ ការកៀរគរប្រភពធនធាន

ប្រភពធនធាន ជាចំណុចប្រឈមមួយរបស់ ម.ម.ជ ក្នុងការពង្រឹង និងពង្រីកប្រតិបត្តិការរបស់ខ្លួនឱ្យឆ្លើយតបនឹងតម្រូវការ។ ប្រភពធនធានរួមមាន៖ ធនធានថវិកា ជំនាញឯកទេស (ជំនួយបច្ចេកទេស) និងធនធានរូបវ័ន្ត (ដូចជា ស្តង់ដារមាត្រាសាស្ត្រ សម្ភារ បរិក្ខា នានា)។ ធនធានទាំងនេះ មានភាពចាំបាច់បំផុត សម្រាប់ ម.ម.ជ ធ្វើប្រតិបត្តិការ និងផ្តល់សេវាមាត្រាសាស្ត្រ ក៏ដូចជាបន្តអភិវឌ្ឍវិស័យមាត្រាសាស្ត្រទាំងមូលឱ្យមានភាពរីកចម្រើន ដូចបណ្តាប្រទេសនានាក្នុងតំបន់ និងពិភពលោក។

បច្ចុប្បន្ន ម.ម.ជ មានប្រភពធនធានសំខាន់ៗ ដូចខាងក្រោម៖

១- ប្រភពពីរាជរដ្ឋាភិបាល៖ មានទាំងថវិកា សម្រាប់ចំណាយប្រាក់បៀវត្សមន្ត្រី និងចំណាយប្រតិបត្តិការ យោងតាមផែនការប្រចាំឆ្នាំ ដែលអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនធានរូបវ័ន្តជាច្រើន (អាគារការិយាល័យ មធ្យោបាយ...) ជាទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវបានបែងចែកមកឱ្យ ម.ម.ជ ប្រើប្រាស់ សម្រាប់បម្រើការងារមាត្រាសាស្ត្រ។

២- ចំណូលពីសេវាសាធារណៈ បានមកពីការទទួលថ្លៃសេវាមាត្រាសាស្ត្រ (ត្រួតពិនិត្យផ្ទៀងផ្ទាត់ ព្យាសកម្ម ផ្តល់អាជ្ញាប័ណ្ណ និងសេវាពាក់ព័ន្ធផ្សេងៗ) ពីអតិថិជនមកពីគ្រប់វិស័យ (ឯកជន និងសាធារណៈ)។

៣- ប្រភពពីដៃគូអភិវឌ្ឍន៍ រួមមាន PTB; NIM, China; UNIDO៖ ភាគច្រើនជាធនធានបច្ចេកទេស សំដៅពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាពរបស់ ម.ម.ជ ដូចជាគាំទ្រឱ្យទទួលបានការវាយតម្លៃទទួលស្គាល់ ការបណ្តុះបណ្តាលសមត្ថភាព ការផ្លាស់ប្តូរបទពិសោធន៍ ការប្រឹក្សាយោបល់ ។ល។ ក្រៅពីនេះ ក៏មានជំនួយជាឧបករណ៍ សម្ភារ (ស្តង់ដារមាត្រាសាស្ត្រ) មួយចំនួន និងថវិកាខ្លះៗដែរ សម្រាប់អនុវត្តគម្រោង/ព្រឹត្តិការណ៍ជាក់លាក់នានា ពាក់ព័ន្ធនឹងអភិវឌ្ឍមាត្រាសាស្ត្រ។

៤- ប្រភពពីបណ្តាញមាត្រាសាស្ត្រអន្តរជាតិ៖ ម.ម.ជ ត្រូវចំណាយថវិកាបង់វិភាគទានសម្រាប់សមាជិកភាព នៃបណ្តាញមាត្រាសាស្ត្រអន្តរជាតិ (ASEAN-EGM, ACCSQ, APMP, APLMF, OIML, BIPM) ហើយធនធាន ដែលទទួលបានមកវិញគឺ ការទំនាក់ទំនង ការផ្លាស់ប្តូរបទពិសោធន៍ ការបណ្តុះបណ្តាលជំនាញ ទ្រឹស្តី និងគោលការណ៍ប្រតិបត្តិល្អ និងឯកទេសនានា សម្រាប់យកមកកែលម្អនិងអភិវឌ្ឍវិស័យមាត្រាសាស្ត្រនៅកម្ពុជា ឱ្យស្របតាមនិយាមដែលទទួលស្គាល់ជាអន្តរជាតិ។

សម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ ម.ម.ជ នឹងពង្រឹងការកៀរគរធនធានបន្ថែមពីប្រភពខាងលើ។ ម.ម.ជ សង្ឃឹមថាតាមរយៈផែនការយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលនឹងទទួលស្គាល់សារសំខាន់នៃវិស័យមាត្រាសាស្ត្រ កាន់តែខ្លាំង ហើយពិចារណាបង្កើនអាទិភាពដល់វិស័យនេះ ដោយបង្កើនការផ្តល់ធនធានបន្ថែមសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍវិស័យនេះឱ្យមានការរីកចម្រើនដូចបណ្តាប្រទេសនានា។

ម.ម.ជ នឹងពង្រីកសេវាកម្មមាត្រាសាស្ត្ររបស់ខ្លួន (ប្រភេទ ចំនួនអតិថិជន) និងកៀរគរធនធានថវិកា តាមរយៈទទួលថ្លៃសេវាកម្មប្រកបដោយតម្លាភាព។ ធនធានថវិកាមួយចំនួននឹងអាចកៀរគរបាន តាមរយៈស្ថាប័នឯកជនជាដៃគូ ដែលទទួលបានអាជ្ញាប័ណ្ណពី ម.ម.ជ ក្នុងការផ្តល់សេវាកម្មមាត្រាសាស្ត្រ។ ម.ម.ជ នឹងកត់ត្រា និងត្រួតពិនិត្យជាប្រចាំ (នូវវឌ្ឍនភាព) ចំពោះចំណូល ចំណាយទាំងនេះ។

ម.ម.ជ នឹងអភិវឌ្ឍសមត្ថភាពមន្ត្រី លើជំនាញសរសេរសំណើ ហើយធ្វើការកៀរគរធនធាននានា ដែលអាចរកបាន (ថវិកាសម្រាប់គាំទ្រសកម្មភាព/ព្រឹត្តិការណ៍ជាក់លាក់ សម្ភារឬឧបករណ៍ ការគាំទ្រលើការអភិវឌ្ឍសមត្ថភាព និងការគាំទ្រពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាព)។

## ជំពូកទី៥៖ ការអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ

### ៥.១. ការអនុវត្តផែនការយុទ្ធសាស្ត្រ

**<u>រចនាសម្ព័ន្ធអនុវត្ត</u>**

ដើម្បីអនុវត្តយុទ្ធសាស្ត្រ ម.ម.ជ ត្រូវរៀបចំរចនាសម្ព័ន្ធ (ក្រុមមន្ត្រីធ្វើការតាមឯកទេស និងជំនាញ) ហើយស្វែងរកទំនាក់ទំនងរវាងរចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រ។ ម.ម.ជ មាននាយកដ្ឋានចំនួន ៤ ការិយាល័យច្រកចេញចូលតែមួយ បានចូលរួមចំណែកទៅដល់យុទ្ធសាស្ត្រ ដូចខាងក្រោម៖




**រូបភាពទី៤៖ ទំនាក់ទំនងរវាងរចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រ**

នាយកដ្ឋាននីមួយៗ មានគោលដៅ និងគោលបំណងជាក់លាក់នានា ដែលត្រូវបំពេញ (ក្របខណ្ឌនៃការងាររបស់នាយកដ្ឋាននីមួយៗ) ដែលរួមចំណែកទៅដល់យុទ្ធសាស្ត្ររបស់ស្ថាប័នទាំងមូល។ តាមការពិភាក្សាអំពីការទទួលខុសត្រូវរបស់នាយកដ្ឋាន ក្នុងការធ្វើឱ្យសម្រេចនូវស្វូចនាករនានារបស់យុទ្ធសាស្ត្រនីមួយៗ នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ និងនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ ដើរតួនាទីជានាយកដ្ឋានកម្មវិធី ដែលមានភារកិច្ចស្នូលក្នុងការផ្តល់សេវាមាត្រាសាស្ត្រ ក្នុងផ្នែកមាត្រាសាស្ត្រដែលគាំទ្រទីផ្សារ និងអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសជាតិ (ព្យាសកម្ម ត្រួតពិនិត្យផ្ទៀងផ្ទាត់...) នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម ដោយបំពេញតួនាទីនានា ដែលគាំទ្រដោយផ្ទាល់ដល់ការអនុវត្តកម្មវិធី និងផ្តល់សេវាកម្មមាត្រាសាស្ត្រ និងនាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ និងការិយាល័យច្រកចេញចូលតែមួយមានតួនាទីផ្តល់ការគាំទ្រទៅដល់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិទាំងមូល។

**<u>ផែនការប្រតិបត្តិប្រចាំឆ្នាំ</u>**

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រវិស័យមាត្រាសាស្ត្រ ម.ម.ជ នឹងបង្កើតផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយបំបែកផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ឱ្យទៅជាផែនការ១ឆ្នាំៗ។ ផែនការប្រតិបត្តិប្រចាំឆ្នាំទី១ នឹងត្រូវបង្កើតនៅចុងឆ្នាំ មុនឆ្នាំអនុវត្ត។ នៅចុងឆ្នាំអនុវត្តនៃឆ្នាំទី១ ម.ម.ជ នឹងធ្វើការប្រជុំបូកសរុបប្រចាំឆ្នាំអំពីផលសម្រេច វឌ្ឍនភាព និងការប្រឈមនានា រួចពិនិត្យឡើងវិញទៅលើផែនការយុទ្ធសាស្ត្រ៥ឆ្នាំ មុននឹងរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ សម្រាប់ឆ្នាំទី២។ ម.ម.ជ នឹងបង្កើតទម្រង់ផ្ទៃក្នុងមួយ សម្រាប់ប្រើប្រាស់ក្នុងការបង្កើតផែនការប្រតិបត្តិ។

## ៥.២. ការត្រួតពិនិត្យ និងវាយតម្លៃ

ការត្រួតពិនិត្យជាការសង្កេត តាមដាន និងឆ្លុះបញ្ចាំងជាប្រចាំ លើផែនការ សកម្មភាព ដើម្បីកំណត់កត្តាជោគជ័យ និងឧបសគ្គរាំង ហើយកែតម្រូវជាបន្តបន្ទាប់ សំដៅបង្កើនប្រសិទ្ធភាពការងារឱ្យសម្រេចគោលដៅ។ ម.ម.ជ បានបង្កើតសូចនាករ និងចំណុចដៅជាក់លាក់ សម្រាប់ធ្វើជាមូលដ្ឋានត្រួតពិនិត្យតាមដាន និងវាយតម្លៃ (សូមមើលឧបសម្ព័ន្ធទី១)។ ម.ម.ជ នឹងបង្កើតក្រុមការងារដែលទទួលខុសត្រូវ ក្នុងការសម្របសម្រួលសកម្មភាពត្រួតពិនិត្យ និងវាយតម្លៃ រួចចាប់ផ្តើមអភិវឌ្ឍសមត្ថភាពក្នុងជំនាញត្រួតពិនិត្យ និងវាយតម្លៃ។ ក្រុមការងារនឹងបង្កើតផែនការត្រួតពិនិត្យ និងវាយតម្លៃ ដោយបញ្ជាក់ពីឧបករណ៍ ឬ វិធីសាស្ត្រច្បាស់លាស់។ សកម្មភាពត្រួតពិនិត្យជាសកម្មភាពផ្ទៃក្នុង ដែលធ្វើឡើងតាមរយៈការកត់ត្រាស្ថិតិ ការប្រជុំឆ្លុះបញ្ចាំង (ត្រីមាស/ឆមាស) ការប្រជុំបូកសរុបប្រចាំឆ្នាំ និងសកម្មភាពចុះសម្ភាសន៍ ឬ ស្រង់ព័ត៌មាន ពីអតិថិជន និងអ្នកពាក់ព័ន្ធ។

ការវាយតម្លៃជាសកម្មភាព ដែលត្រូវធ្វើឡើងដោយអ្នកវាយតម្លៃឯករាជ្យពីខាងក្រៅ ដែលមានឯកទេស និងបទពិសោធន៍វាយតម្លៃ។ លក្ខខណ្ឌយោង (TOR) នឹងត្រូវរៀបចំបម្រើឱ្យការវាយតម្លៃ ដើម្បីវិនិច្ឆ័យលទ្ធផលរួមសម្រាប់កំឡុងពេលវែង (ឥទ្ធិពលនៃការប្រើប្រាស់សេវាមាត្រាសាស្ត្រ គុណភាព និងប្រសិទ្ធភាព នៃសេវាមាត្រាសាស្ត្ររបស់ ម.ម.ជ និងចំណុចពាក់ព័ន្ធ) និងកំណត់មេរៀនទទួលបាន សម្រាប់កែលម្អយុទ្ធសាស្ត្រនាកំឡុងពេល ឬអាណត្តិបន្ទាប់។ ម.ម.ជ នឹងរៀបចំការវាយតម្លៃយ៉ាងតិចម្តង នៅចុងឆ្នាំទី៥ នៃការអនុវត្តផែនការយុទ្ធសាស្ត្រ។

## ជំពូកទី៦៖ សេចក្តីសន្និដ្ឋាន

មាត្រាសាស្ត្រពិតជាមានសារសំខាន់ ដល់វិស័យពាក់ព័ន្ធជាច្រើន ក្នុងការលើកកម្ពស់គុណភាព ផលិតកម្ម បង្កើនសមត្ថភាពការប្រកួតប្រជែងនៅលើទីផ្សារ ការពារផលប្រយោជន៍ និងជានាភាពយុត្តិធម៌ក្នុងពាណិជ្ជកម្ម និងធានាសុវត្ថិភាព សុខភាព និងបរិស្ថាន ដែលទាំងអស់នេះជាមូលដ្ឋានដ៏រឹងមាំគាំទ្រដល់ការលូតលាស់សេដ្ឋកិច្ចជាតិ បង្កើតការងារ និងប្រាក់ចំណូល និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។ មាត្រាសាស្ត្រជាវិទ្យាសាស្ត្រនៃទម្ងន់ និងរង្វាស់រង្វាល់ ដែលមានន័យទូលំទូលាយ និងតម្រូវឱ្យមានការប្រតិបត្តិទៅតាមនិយាម ដែលទទួលស្គាល់ជាអន្តរជាតិ។

វិស័យមាត្រាសាស្ត្រនៅកម្ពុជា មានការអភិវឌ្ឍយឺតនៅឡើយ បើប្រៀបធៀបទៅនឹងប្រទេសក្នុងតំបន់ និងក្នុងពិភពលោក។ មានការប្រឈមជាច្រើន ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ជាពិសេស និងដោះស្រាយទាំងសមត្ថភាពអង្គភាពមាត្រាសាស្ត្រជាតិ និងគុណភាព ព្រមទាំងវិសាលភាព នៃការផ្តល់សេវាកម្មមាត្រាសាស្ត្រ។ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមានតួនាទីដ៏ធំធេង ក្នុងការអភិវឌ្ឍ និងផ្តល់សេវាកម្មមាត្រាសាស្ត្រ ប្រកបដោយប្រសិទ្ធភាព ដើម្បីជាគុណប្រយោជន៍ក្នុងការអភិវឌ្ឍវិស័យដទៃ និងចំពោះសង្គមជាតិ។ សម្រាប់ ៥ ឆ្នាំខាងមុខ ចាត់ទុកជាកំឡុងពេល នៃការពង្រឹង និងពង្រីកវិសាលភាព និងគុណភាព នៃការផ្តល់សេវាកម្មមាត្រាសាស្ត្រ ដែលប្រការនេះតម្រូវឱ្យមានការបន្តអភិវឌ្ឍ និងពង្រឹងសមត្ថភាព និងមានធនធានគ្រប់គ្រាន់ សម្រាប់ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ដើម្បីរួមចំណែកពង្រឹងហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ និងឆ្លើយតបនឹងតម្រូវការរបស់ផ្នែកឧស្សាហកម្ម និងផលិតកម្ម ជាពិសេសសហគ្រាសធុនតូច និងមធ្យម។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ ២០២៣-២០២៧ លើកទីមួយនេះ នឹងក្លាយជាផែនទីបង្ហាញផ្លូវដ៏សំខាន់មួយ សម្រាប់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិយកមកធ្វើជាមគ្គុទេសក៍ ក្នុងការបង្កើតផែនការប្រតិបត្តិ និងអនុវត្ត ក៏ដូចជាសម្រាប់ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ក្នុងការចូលរួមគាំទ្រតាមរូបភាពដែលអាចធ្វើទៅបាន ដើម្បីអភិវឌ្ឍវិស័យមាត្រាសាស្ត្រនៅកម្ពុជាឱ្យមានការរីកចម្រើន។ នាយកដ្ឋានប្រតិបត្តិទាំងបួន រួមទាំងការិយាល័យច្រកចេញចូលតែមួយ របស់ ម.ម.ជ នឹងរួមចំណែកអនុវត្តដោយផ្ទាល់ចំពោះផែនការយុទ្ធសាស្ត្រនេះ ហើយជំនាញ និងការតាំងចិត្តរបស់មន្ត្រីក្នុងនាយកដ្ឋាននីមួយៗ និងការិយាល័យច្រកចេញចូលតែមួយគឺជាគន្លឹះជោគជ័យ ក្នុងការសម្រេចសូចនាកររបស់ផែនការយុទ្ធសាស្ត្រ។

យើងសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួងគ្រប់លំដាប់ថ្នាក់ មន្ត្រីរបស់ ម.ម.ជ ដៃគូអភិវឌ្ឍន៍ និងស្ថាប័នគាំទ្រដ៏ទៃទៀត នឹងចាប់អារម្មណ៍ និងមានការយកចិត្តទុកដាក់ចំពោះផែនការយុទ្ធសាស្ត្រនេះ ព្រមទាំងផ្តល់កិច្ចសហការយ៉ាងពេញទំហឹង ក្នុងការគាំទ្រដល់ការធ្វើឱ្យសម្រេចបាននូវយុទ្ធសាស្ត្រនានា ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រនេះ។

# ឧបសម្ព័ន្ធទី១៖ ម៉ាទ្រិកសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃ

## យុទ្ធសាស្ត្រទី១៖ សេវាកម្មមាត្រាសាស្ត្រដែលជួយគាំទ្រទីផ្សារ

| សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា | ចំនួនដៅ តាមឆ្នាំ | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | |
| **១.១. សិក្សាតម្រូវការ និងកំណត់អាទិភាព** | | | | | | | | D/MSC-D/LGM |
| ១.១.១. ចំនួននៃការសិក្សាតម្រូវការ | ដង | - | ១ | ១ | ១ | ១ | ១ | D/MSC-D/LGM |
| ១.១.២. ចំនួនរបាយការណ៍លទ្ធផលនៃការសិក្សាតម្រូវការ | រ.ប | - | ១ | ១ | ១ | ១ | ១ | D/MSC-D/LGM |
| ១.១.៣. ចំនួនប្រភេទសេវាត្រូវការថ្មីដែលបានកំណត់ និងចាត់អាទិភាព | ប្រភេទ | - | - | ២ | ២ | ២ | ២ | D/MSC (D/LGM) |
| | | | | | | | | |
| **១.២. បន្តអភិវឌ្ឍ និងពង្រឹងសមត្ថភាពមន្ទីរពិសោធន៍មាត្រាសាស្ត្រ** | | | | | | | | D/MSC |
| ១.២.១. ចំនួនឧបករណ៍មាត្រាសាស្ត្រគាំទ្រប្រភេទសេវាមានការកើន | គ្រឿង | - | ៦ | ៦ | ៦ | ៦ | ៦ | D/MSC |
| ១.២.២. ចំនួនមន្ទីរពិសោធន៍ដែលបានបង្កើតថ្មី | មន្ទីរ.ព | - | ១ | - | ១ | - | ១ | D/MSC |
| ១.២.៣. ចំនួន ISO/IEC 17025 ដែលបានទទួល | ប្រភេទ | - | ២ | - | ២ | - | ២ | D/MSC |
| | | | | | | | | |
| **១.៣. ពង្រីកវិសាលភាពសេវាកម្មមាត្រាសាស្ត្រ** | | | | | | | | D/MSC |
| ១.៣.១. ចំនួនលិខិតបទដ្ឋានគតិយុត្ត សម្រាប់ដំណើរការសេវា | ច្បាប់ បទដ្ឋាន | - | ២ | ២ | ២ | ២ | ២ | D/MSC |
| ១.៣.២.ចំនួនសេវាបង្កើតថ្មី ដែលដាក់ឱ្យដំណើរការ | សេវា | - | ២ | ២ | ២ | ២ | ២ | D/MSC |
| ១.៣.៣. ចំនួនឧបករណ៍ដែលបានព្យាសកម្ម ដោយ ម.ម.ជ | គ្រឿង | ៨០០ | ៨៥០ | ៩០០ | ១០០០ | ១១០០ | ១២០០ | D/MSC |
| ១.៣.៤. កំណើនអតិថិជន (ក្រុមហ៊ុន)ដែលបានទទួលសេវា ព្យាសកម្មពី ម.ម.ជ | ភាគរយ % | ១៥០ ក្រុមហ៊ុន | ១០ | ១០ | ១០ | ១០ | ១០ | D/MSC |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១.៣.៥. ចំនួនឧបករណ៍បានព្យាសកម្ម ដោយវិទ្យាស្ថានមាត្រា សាស្ត្រដទៃក្រោមការសម្របសម្រួល របស់ ម.ម.ជ | គ្រឿង | - | - | - | ៣ | ៦ | ៦ | D/MSC |
| ១.៣.៦. ចំនួនករណីពិគ្រោះយោបល់/បណ្តុះបណ្តាលដែលបានផ្តល់ | ដង | - | ៣ | ៣ | ៣ | ៣ | ៣ | D/MSC |
| | | | | | | | | |
| **១.៤. កសាងភាពជាដៃគូសម្រាប់ផ្តល់សេវាកម្មមាត្រាសាស្ត្រ** | | | | | | | | D/INM ,D/MSC |
| ១.៤.១. ក្របខ័ណ្ឌគតិយុត្តសម្រាប់ការផ្តល់សិទ្ធត្រូវបានបង្កើត | បទដ្ឋាន | - | ១ | - | - | - | - | D/INM, D/MSC |
| ១.៤.២. ចំនួនស្ថាប័ន អង្គភាព ក្រុមហ៊ុន ដែលបានទទួលសិទ្ធ ក្នុងការផ្តល់សេវាកម្មមាត្រាសាស្ត្រ | ស្ថាប័ន | - | ១ | ៣ | ៦ | ៩ | ១២ | D/INM, D/MSC |
| ១.៤.៣. ចំនួនសេវាដែលអាចផ្តល់ដោយស្ថាប័ន អង្គភាព និងក្រុមហ៊ុនដៃគូ | សេវា | - | ២ | ៦ | ១២ | ១៨ | ២៤ | D/INM, D/MSC |
| ១.៤.៤. ចំនួនស្ថាប័នមាត្រាសាស្ត្រអន្តរជាតិ ដែលបានចុះកិច្ច ព្រមព្រៀងក្នុងការផ្តល់សេវាមាត្រាសាស្ត្រដល់អតិថិជនកម្ពុជា (តាមរយៈ ម.ម.ជ) | ស្ថាប័ន | - | - | ១ | ២ | - | - | D/INM, D/MSC |
| | | | | | | | | |
| **១.៥. បង្កើត និងកែសម្រួលនិតិវិធីប្រតិបត្តិការងារ (SOP)** | | | | | | | | D/MSC |
| ១.៥.១. ចំនួននីតិវិធីប្រតិបត្តិ (SOP) ដែលបានបង្កើត | SOP | - | ២ | ២ | ២ | ២ | ២ | D/MSC |
| ១.៥.២. ចំនួននីតិវិធីប្រតិបត្តិ (SOP) ដែលបានកែសម្រួល | SOP | - | ៨ | ៦ | ៥ | ៣ | ២ | D/MSC |
| | | | | | | | | |
| **១.៦. ធ្វើទំនើបកម្ម/វិធីថ្មីលនៃការផ្តល់សេវា (ឱ្យលឿន/រហ័ស)** | | | | | | | | OWS (D/MSC, D/LGM, D/INM, D/MLA) |
| ១.៦.១. លិខិតបទដ្ឋានគតិយុត្ត ក្នុងការធ្វើទំនើបកម្ម | បទដ្ឋាន | - | - | ១ | ១ | ១ | ១ | OWS |
| ១.៦.២. ការដាក់ពាក្យសុំសេវា អនឡាញ | ពាក្យសុំ | - | - | - | ២០០ | ៣០០ | ៤០០ | OWS |
| ១.៦.៣. កម្មវិធីបង់ប្រាក់ - ដំណើរការអនឡាញ | កម្មវិធី | - | - | ១ | - | - | - | OWS |
| ១.៦.៤. ចុះបញ្ជីឧបករណ៍មាត្រាសាស្ត្រ និងផ្តល់អាជ្ញាប័ណ្ណ - អនឡាញ | សេវា | - | - | - | ៦០០ | ៦៣០ | ៦៦០ | OWS |
| ១.៦.៥. លទ្ធផល និងវិញ្ញាបនបត្រ - អនឡាញ ឬ ផ្ទាល់ | អតិថិជន | - | - | - | ៦៣០ | ៦៦០ | ៦៦០ | OWS |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១.៦.៦. ចំនួនអតិថិជន ដែលបានកើន | % | - | ១០ | ១០ | ១០ | ១០ | ១០ | OWS |
| | | | | | | | | |
| **១.៧. លើកកម្ពស់កិច្ចសហប្រតិបត្តិការ ជាមួយវិស័យឯកជន** | | | | | | | | D/INM, D/MSC, D/LGM, D/MLA |
| ១.៧.១. ចំនួន Quality/Metrology Talk ដែលបានរៀបចំ | ដង | - | ៣ | - | ៦ | - | ៩ | D/INM |
| ១.៧.២. ចំនួនសិក្ខាសាលាផ្សព្វផ្សាយប្រយោជន៍សេវាមាត្រាសាស្ត្រ | ដង | - | ៤ | ៤ | ៤ | ៤ | ៤ | D/INM |
| ១.៧.៣. បញ្ជីឈ្មោះក្រុមហ៊ុន វិស័យឯកជន ដែលបានចងក្រង | បញ្ជី | - | ១ | - | ១ | - | ១ | D/INM |
| ១.៧.៤. ក្រុមការងារសម្រាប់ទំនាក់ទំនងជាមួយវិស័យឯកជន បានបង្កើត | ក្រុម | - | ១ | - | - | - | - | D/INM |
| ១.៧.៥. ចំនួនវេទិកាពិគ្រោះយោបល់ជាមួយវិស័យឯកជន | វេទិកា | - | - | ១ | - | ១ | ១ | D/INM |
| | | | | | | | | |
| **១.៨. បង្កើត និងដាក់ឱ្យដំណើរការយន្តការផ្តល់យោបល់ត្រឡប់** | | | | | | | | OWS, D/INM, D/MSC, D/LGM, D/MLA |
| ១.៨.១. ទម្រង់ផ្តល់យោបល់តាមអនឡាញបានបង្កើតនិងប្រើប្រាស់ | ទម្រង់ | - | - | - | ១ | - | - | OWS, D/INM, D/MSC, D/LGM, D/MLA |
| ១.៨.២. ទម្រង់ផ្តល់យោបល់(hard)ឬបញ្ជីសំណួរ ត្រូវបានបង្កើត | ទម្រង់ | - | - | - | ១ | - | - | OWS, D/INM, D/MSC, D/LGM, D/MLA |
| ១.៨.៣. ចំនួននៃការប្រមូលយោបល់ពីអ្នកប្រើប្រាស់សេវា | ដង | - | - | - | - | ១ | ១ | OWS, D/INM, D/MSC, D/LGM, D/MLA |

## យុទ្ធសាស្ត្រទី២៖ ពង្រឹងការអនុវត្តច្បាប់ស្ដីពីមាត្រាសាស្ត្រ

| សូចនាករ | ឯកតា | ទិន្នន័យដើមគ្រា | ចំនួនដៅ តាមឆ្នាំ | | | | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | |
| **២.១. បន្តអភិវឌ្ឍ ពង្រឹងនិងពង្រីកមធ្យោបាយ/ស្តង់ដារ ត្រួតពិនិត្យផ្ទៀងផ្ទាត់** | | | | | | | | D/LGM |
| ២.១.១. ចំនួនស្តង់ដារប្រតិបត្តិមានការកើនឡើង | % | ២១២ | ៥ | ៥ | ៥ | ៥ | ៥ | D/LGM |
| ២.១.២. ចំនួនមធ្យោបាយ (Facilities) ត្រួតពិនិត្យផ្ទៀងផ្ទាត់ដែល បានបង្កើតថ្មី | ឈុត | ៦ | ១ | ១ | ១ | ១ | ១ | D/LGM |
| ២.១.៣. ចំនួន ISO/IEC 17020 ត្រូវបានទទួល | ប្រភេទ | - | ១ | ១ | ១ | ១ | ១ | D/LGM |
| | | | | | | | | |
| **២.២. ពង្រឹង និងពង្រីកវិសាលភាពសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់** | | | | | | | | D/LGM (D/MLA) |
| ២.២.១. ចំនួនលិខិតបទដ្ឋានគតិយុត្តបច្ចេកទេសសម្រាប់ដំណើរការសេវា | បទដ្ឋាន | ៨ | ១ | ១ | ១ | ១ | ១ | D/LGM |
| ២.២.២. ចំនួនសិក្ខាសាលា/ផ្សព្វផ្សាយ (ច្បាប់ ឬបទប្បញ្ញត្តិ ពាក់ព័ន្ធ) | វគ្គ | ១៥ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | D/LGM, D/MLA |
| ២.២.៣. ចំនួនសេចក្ដីជូនដំណឹងដល់វិស័យឯកជនស្ដីពីការអនុវត្ត ច្បាប់ | ច្បាប់ | ២ | ៥ | ៥ | ៥ | ៥ | ៥ | D/LGM |
| ២.២.៤. ចំនួនសេវាបង្កើតថ្មី ដែលដាក់ឱ្យដំណើរការ | សេវា | - | ១ | ១ | ១ | ១ | ១ | D/LGM |
| ២.២.៥. កំណើនឧបករណ៍មាត្រាសាស្ត្រ ដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់ដោយ ម.ម.ជ | % | ៥០០ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | D/LGM |
| ២.២.៦. កំណើនសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់លើទំនិញផលិតនិង ទំនិញវេចខ្ចប់ | % | ៤៦០ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | D/LGM |
| ២.២.៧. ចំនួននៃតាមដានការកែប្រែរបស់អតិថិជន ក្រោយពេលត្រួតពិនិត្យផ្ទៀងផ្ទាត់ | ដង | - | ៥០ | ៥០ | ៥០ | ៥០ | ៥០ | D/LGM |
| ២.២.៨. ចំនួននៃការលើកសំណើ ក្នុងការកែលម្អ/ធ្វើវិសោធនកម្មលិខិតបទដ្ឋាគតិយុត្តពាក់ព័ន្ធនឹងមាត្រាសាស្ត្រ | ដង | ៧ | ១ | ១ | ១ | ១ | ១ | D/LGM (D/MLA) |
| | | | | | | | | |
| **២.៣. កសាងភាពជាដៃគូសម្រាប់ផ្តល់សេវាត្រួតពិនិត្យផ្ទៀងផ្ទាត់** | | | | | | | | D/LGM |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២.៣.១. ក្របខ័ណ្ឌគតិយុត្តសម្រាប់ការផ្តល់សិទ្ធត្រូវបានបង្កើត | ច្បាប់ | - | - | - | - | - | - | D/LGM |
| ២.៣.២. ចំនួនស្ថាប័ន អង្គភាព ក្រុមហ៊ុន ដែលបានទទួលសិទ្ធ ក្នុងការផ្តល់សេវាត្រួតពិនិត្យផ្ទៀងផ្ទាត់ | ស្ថាប័ន | - | - | ២ | ២ | ២ | ២ | D/LGM |
| ២.៣.៣. ចំនួនសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់ ដែលផ្តល់ដោយស្ថាប័ន អង្គភាព និងក្រុមហ៊ុនដៃគូ | សេវា | - | - | ៤ | ៤ | ៤ | ៤ | D/LGM |
| | | | | | | | | |
| **២.៤. បង្កើត និងធ្វើបច្ចុប្បន្នភាព និតិវិធីប្រតិបត្តិ (SOP) សម្រាប់ ពង្រឹងការអនុវត្តច្បាប់** | | | | | | | | D/LGM |
| ២.៤.១. ចំនួននីតិវិធីប្រតិបត្តិ (SOP) ដែលបានបង្កើត | SOP | ៥ | ១ | ១ | ១ | ១ | ១ | D/LGM |
| ២.៤.២. ចំនួននីតិវិធីប្រតិបត្តិ (SOP) ដែលបានធ្វើបច្ចុប្បន្នភាព | SOP | ១ | ១ | ១ | ១ | ១ | ១ | D/LGM |
| ២.៤.៣. ចំនួន SOP ដែលបានអនុវត្ត | SOP | ៥ | ១ | ១ | ១ | ១ | ១ | D/LGM |
| | | | | | | | | |
| **២.៥. ពង្រឹងយន្តការក្នុងការការពារអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់** | | | | | | | | D/LGM, D/INM, D/MLA, D/MSC |
| ២.៥.១. ចំនួនលិខិតបទដ្ឋានគតិយុត្ត សម្រាប់នីតិវិធីពិនិត្យ បទល្មើសមាត្រាសាស្ត្រ ដែលបានបង្កើត | លិខិត | - | ១ | - | - | - | - | D/LGM, D/INM, D/MLA |
| ២.៥.២. ចំនួននៃការចុះតាមដានទីផ្សារ និងផលិតកម្ម (Market surveillance) | ដង | - | ២៥ | ២៥ | ២៥ | ២៥ | ២៥ | D/LGM |
| ២.៥.៣. ប្រព័ន្ធទំនាក់ទំនងសម្រាប់ Public complaint ត្រូវបាន បង្កើត | ប្រព័ន្ធ | ២ | ១ | ១ | ១ | ១ | ១ | D/LGM |
| ២.៥.៤. ចំនួនឧបករណ៍មាត្រាសាស្ត្រ ដែលបានជួសជុល កែតម្រូវ | % | - | ៣ | ៣ | ៣ | ៣ | ៣ | D/LGM |
| ២.៥.៥. ចំនួនមុខទំនិញផលិត និងទំនិញវេចខ្ចប់ ដែលបានកែតម្រូវ | % | - | ១ | ១ | ១ | ១ | ១ | D/LGM |
| ២.៥.៦. ចំនួនបុគ្គល/មូលដ្ឋានដែលបានធ្វើពិន័យអន្តរការណ៍ | បុគ្គល/ មូលដ្ឋាន | - | ៥០ | ៤០ | ៣០ | ២៥ | ២៥ | D/LGM |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| **២.៦. បង្កើត និងអនុវត្តប្រព័ន្ធអនុម័តគំរូ** | | | | | | | | D/MSC (D/LGM, D/INM) |
| ២.៦.១. លិខិតបទដ្ឋានគតិយុត្តិសម្រាប់អនុម័តគំរូ បានបង្កើតឡើង | បទដ្ឋាន | - | ១ | ១ | ១ | ១ | ១ | D/MSC |
| ២.៦.២. ចំនួនគំរូឧបករណ៍ដែលទទួលបានការទទួលស្គាល់ការ អនុម័តគំរូ | គ្រឿង | - | - | ២ | ២ | ២ | ២ | D/MSC |
| ២.៦.៣. ចំនួនវិញ្ញាបនប័ត្រដែលបានទទួលស្គាល់ (Certification System) | វិញ្ញាបនបត្រ | - | ១ | ១ | ១ | ១ | ១ | D/LGM |
| ២.៦.៤. នីតិវិធីទទួលស្គាល់ការអនុម័តគំរូ នៃបណ្ដាវិទ្យាស្ថានមាត្រាសាស្ត្រ ក្នុងតំបន់ និងសកល | នីតិវិធី | - | - | ១ | ១ | ១ | ១ | D/MSC, D/LGM |
| | | | | | | | | |
| **២.៧. បង្កើនការផ្ដល់សេវា នាំចូល ផលិត តម្លើង ជួសជុល ឧបករណ៍មាត្រាសាស្ត្រ ទំនិញវេចខ្ចប់ ចុះបញ្ជីមាត្រាសាស្ត្រ ប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា និងបញ្ជាក់ ជំនាញមាត្រាសាស្ត្រ** | | | | | | | | D/INM, D/MLA, D/LGM |
